ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ផែនការសកម្មភាព ស្តីពី ការអប់រំពហុភាសា ២០១៩-២០២៣

ឆ្នាំ២០១៩

# ផែនការសកម្មភាព

# ស្តីពី

# ការអប់រំពហុភាសា

# ២០១៩-២០២៣

## អារម្ភកថា

ក្រសួងអប់រំ យុវជន និងកីឡា បានសហការជាមួយដៃគូអភិវឌ្ឍនានារៀបចំផែនការសកម្មភាពស្តីពីការអប់រំពហុភាសា២០១៩-២០២៣ ដើម្បីឆ្លើយតបទៅនឹងអនុសញ្ញាស្តីពីសិទ្ធិកុមារ ដែលជាក្របខណ្ឌច្បាប់របស់អង្គការសហប្រជាជាតិ គោលដៅអភិវឌ្ឍប្រកបដោយចីរភាពទី៤ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច ច្បាប់ស្តីពីការអប់រំ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ ធានាឱ្យកុមារគ្រប់រូបមកពីសហគមន៍ជនជាតិដើមភាគតិចទទួលបានការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។

ផែនការសកម្មភាពស្តីពីការអប់រំពហុភាសាមានគោលបំណងជួយកុមារជនជាតិដើមភាគតិចគ្រប់រូប ដើម្បីបណ្តុះការអប់រំឱ្យមានវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ចូលរួមអភិវឌ្ឍសង្គមជាតិធានាឱ្យមានការចូលរួម ការប្តេជ្ញាចិត្ត និងការផ្តល់ចក្ខុវិស័យរួមពីគ្រប់ភាគីពាក់ព័ន្ធ និងដៃគូអភិវឌ្ឍទាំងអស់។

ផែនការសកម្មភាពស្តីពីការអប់រំពហុភាសានេះ គាំទ្រដល់ការផ្តួចផ្តើម និងវឌ្ឍនភាពរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលមានវិសាលភាពគ្របដណ្តប់ការអប់រំពហុភាសាសម្រាប់កុមារជនជាតិដើមភាគតិច ចាប់ពីកម្រិតមត្តេយ្យសិក្សា បឋមសិក្សា និងអប់រំក្រៅប្រព័ន្ធនៅខេត្តរតនគិរី មណ្ឌលគិរី ក្រចេះ ស្ទឹងត្រែង និងខេត្តព្រះវិហារ និងអនុវត្តចំពោះភាសាកំណើតចំនួនប្រាំមួយរួមមាន ភាសាព្រៅ ព្នង កាវ៉ែត គ្រឹង ទំពួន និងចារាយ។

**ផែនការសកម្មភាពស្តីពីការអប់រំពហុភាសាមានគោលដៅរួមៈ**

- ពង្រីកសេវាអប់រំពហុភាសាប្រកបដោយសមធម៌ បរិយាបន្ន និងមាននិរន្តរភាពដល់ជនជាតិដើមភាគតិច ជាពិសេសកុមារ
- ពង្រឹងការអប់រំពហុភាសាឱ្យមានគុណភាព ដោយផ្សារភ្ជាប់នឹងភាសាកំណើត វប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់របស់ជនជាតិដើមភាគតិច
- លើកកម្ពស់ការចូលរួមរបស់សហគមន៍ជនជាតិដើមភាគតិច និងកិច្ចសហប្រតិបត្តិការគ្រប់ភាគីពាក់ព័ន្ធ។

ការកសាងផែនការសកម្មភាពស្តីពីការអប់រំពហុភាសាបានដាក់បញ្ចូលចក្ខុវិស័យ គោលបំណង វិសាលភាព គោលដៅ យុទ្ធសាស្ត្រ សកម្មភាព សូចនាករ ចំណុចដៅ ក្របខណ្ឌពេលវេលា អង្គភាពទទួលខុសត្រូវចម្បង ស្ថាប័នផ្តល់ការគាំទ្រ ប្រភពជំនួយ ថវិកា ការពិនិត្យតាមដាន និងវាយតម្លៃ និងប្រភពសម្រាប់ផ្ទៀងផ្ទាត់ ដើម្បីអនុវត្តពីឆ្នាំ២០១៩ ដល់២០២៣។

ក្រសួងអប់រំ យុវជន និងកីឡា សូមអំពាវនាវដល់ស្ថាប័ន និងដៃគូអភិវឌ្ឍពាក់ព័ន្ធចូលរួមយ៉ាងសកម្មក្នុងការអនុវត្តផែនការសកម្មភាពនេះ។ នាយកដ្ឋានពាក់ព័ន្ធ មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ត្រូវរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំឱ្យបានសមស្របដោយផ្អែកលើផែនការសកម្មភាពស្តីពីការអប់រំពហុភាសា២០១៩-២០២៣ តាមរយៈកិច្ចសហការជាមួយដៃគូអភិវឌ្ឍ និងសហគមន៍ក្នុងខេត្តនៃតំបន់ខ្ពង់រាបភាគឦសាន ដើម្បីអនុវត្តកម្មវិធីអប់រំពហុភាសាប្រកបដោយជោគជ័យ និងប្រសិទ្ធភាពខ្ពស់។

ថ្ងៃ ព្រហស្បតិ៍ ១៥កើត ខែ ស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ២០១៩

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

# មាតិកា


| | | |
|---|---|---|
| | សារលិខិត | ១ |
| ១ | ចក្ខុវិស័យ | ៤ |
| ២ | គោលបំណង | ៤ |
| ៣ | វិសាលភាព | ៤ |
| ៤ | គោលដៅ | ៤ |
| ៥ | យុទ្ធសាស្ត្រ | ៤ |
| ៦ | ផែនការសកម្មភាព | ៥ |
| ៧ | ការពិនិត្យតាមដានការអនុវត្តផែនការសកម្មភាព ស្តីពីការអប់រំពហុភាសា២០១៩-២០២៣ | ២៦ |
| ៨ | គម្រោងចំណាយតាមយុទ្ធសាស្ត្រ | ២៦ |
| ៩ | សេចក្តីសន្និដ្ឋាន | ២៧ |
| ១០ | ឧបសម្ព័ន្ធ | ២៨ |
| ១០.១ | បញ្ជីពាក្យកាត់ | ២៨ |
| ១០.២ | សទ្ទានុក្រម | ២៩ |
| ១០.៣ | អត្ថប្រយោជន៍ នៃការអប់រំពហុភាសា | ៣០ |
| ១០.៤ | អនុសាសន៍វាយតម្លៃផែនការសកម្មភាពជាតិ ស្តីពីការអប់រំពហុភាសា២០១៥-២០១៨ | ៣១ |
| ១០.៥ | ស្ថិតិជនជាតិដើមភាគតិចនៅប្រទេសកម្ពុជា | ៣៣ |
| ១០.៦ | គំរូអប់រំពហុភាសាសម្រាប់ការអប់រំក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធនៅកម្ពុជា | ៣៣ |
| ១០.៧ | ចំណោលចំនួនសាលារៀន គ្រូ និងសិស្សអប់រំពហុភាសា | ៣៤ |
| ១០.៨ | ចំណោលចំនួនសិស្សជនជាតិដើមភាគតិចទទួលអាហារូបករណ៍ | ៣៨ |

# សារចារ

ព្រះរាជាណាចក្រកម្ពុជាមានជនជាតិដើមភាគតិចដូចជា ព្នង កួយ ទំពួន ចារាយ គ្រឹង ព្រៅ កាវ៉ែត ស្មៀង ក្រោល មិល កាចក់ ព័រ ខោញ ជង សួយ ថ្មូន លុន ស្អូច រដែ ខិ អរេង ស្ទុង ល្មឺន សំរែ និងជនជាតិដើមភាគតិចផ្សេងៗទៀត។ ជនជាតិដើមភាគតិចទាំងអស់ (ប្រមាណជាង១ភាគរយនៃចំនួនប្រជាជនសរុប) រស់នៅក្នុងខេត្តមួយចំនួនដូចជាខេត្តរតនគិរី មណ្ឌលគិរី ក្រចេះ ព្រះវិហារ កំពង់ធំ ស្ទឹងត្រែង ឧត្តរមានជ័យ កំពង់ចាម ពោធិ៍សាត់ កំពង់ស្ពឺ កោះកុង បាត់ដំបង ព្រះសីហនុ បន្ទាយមានជ័យ សៀមរាប និងតំបន់ផ្សេងៗទៀត។ នៅខេត្តនៃតំបន់ខ្ពង់រាបភាគឦសានទាំង៥ (ខេត្តរតនគិរី មណ្ឌលគិរី ក្រចេះ ស្ទឹងត្រែង និងខេត្តព្រះវិហារ) មានជនជាតិដើមភាគតិចចំនួនប្រមាណជាង១០ក្រុមដែលមានប្រជាជនសរុបប្រមាណ១៨៣ ២៨២នាក់ រួមទាំងមានកុមារអាយុពី៣ ដល់៥ឆ្នាំប្រមាណ១៤ ៩២៥នាក់ និងមានកុមារអាយុពី៦ ដល់១៧ឆ្នាំ ប្រមាណ៦៧ ៥២៧នាក់ (ឧបសម្ព័ន្ធ ១០.៥)។

ជនជាតិដើមភាគតិចនៅខេត្តនៃតំបន់ខ្ពង់រាបភាគច្រើនរស់នៅតាមភូមិដាច់ស្រយាលក្នុងកម្រិតដង់ស៊ីតេទាប ដែលមានផ្លូវគមនាគមន៍ មធ្យោបាយធ្វើដំណើរមានការលំបាក ហើយពឹងផ្អែកទាំងស្រុងទៅលើបរិស្ថានធម្មជាតិ រួមទាំងមានសេវាសុខភាព និងសេវាអប់រំតិចតួច ជាហេតុធ្វើឱ្យចំណេះដឹង និងការអប់រំរបស់ពួកគាត់នៅមានកម្រិត។

ជនជាតិដើមភាគតិចទាំងនោះ ប្រកាន់យកវប្បធម៌ ទំនៀមទម្លាប់ ប្រពៃណី ជំនឿ និងភាសាផ្សេងៗគ្នា ទៅតាមក្រុមរបស់ខ្លួន និងមានឱកាសតិចតួចក្នុងការធ្វើទំនាក់ទំនងជាមួយសង្គមខ្មែរទូទៅ។ ការប្រើប្រាស់ភាសាផ្ទាល់ខ្លួនរបស់ក្រុមជនជាតិដើមភាគតិចនីមួយៗរបស់ពួកគាត់មានភាពខុសគ្នានឹងភាសាខ្មែរ ហើយមានតែមួយចំនួនតូចប៉ុណ្ណោះចេះនិយាយ ឬយល់ភាសាខ្មែរដែលជាភាសាជាតិផ្លូវការរបស់ប្រទេសកម្ពុជា។ នៅពេលកុមារជនជាតិដើមភាគតិចចាប់ផ្តើមចូលសាលារៀន គ្រូប្រើប្រាស់ភាសាជាតិជាភាសាមួយដែលពួកគាត់មិនយល់ ជារឿយៗកុមារជាច្រើននាក់បានប្រឡងធ្លាក់ រៀនត្រួតថ្នាក់ និងបោះបង់ការសិក្សា។ កត្តាទាំងនេះបានជំរុញឱ្យយើងទាំងអស់គ្នាចូលរួម និងយកចិត្តទុកដាក់ក្នុងការដោះស្រាយ។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៣១ ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីកិច្ចដូចគ្នាទាំងអស់ដោយឥតប្រកាន់ជាតិសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ។ មាត្រា៦៧ លើកឡើងពីការអនុវត្តកម្មវិធីសិក្សា និងគោលការណ៍គរុកោសល្យទំនើប រាប់បញ្ចូលទាំងបច្ចេកវិទ្យា និងភាសាបរទេស។ មាត្រា៦៨ រដ្ឋផ្តល់ការអប់រំកម្រិតបឋមសិក្សា និងមធ្យមសិក្សានៅសាលារៀនសាធារណៈសម្រាប់ពលរដ្ឋគ្រប់រូបដោយឥតបង់ថ្លៃ ដើម្បីផ្តល់លទ្ធភាពឱ្យប្រជាពលរដ្ឋទាំងអស់ទទួលបានការអប់រំយ៉ាងតិចប្រាំបួនឆ្នាំ។

រាជរដ្ឋាភិបាលបានរៀបចំច្បាប់ស្តីពីការអប់រំ ដែលបានអនុម័តនៅឆ្នាំ២០០៧ មានគោលបំណងអភិវឌ្ឍធនធានមនុស្សដោយផ្តល់ការអប់រំពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។ មាត្រា២៤ ភាសាខ្មែរជាភាសាយាន និងជាមុខវិជ្ជាមួយនៃកម្មវិធីសិក្សាគោលនៅក្នុងសាលារៀនចំណេះទូទៅសាធារណៈ ហើយភាសាសម្រាប់ប្រើប្រាស់ចំពោះអ្នកសិក្សាសញ្ជាតិខ្មែរ ដែលមានដើមកំណើតជាខ្មែរជនជាតិដើមភាគតិច ត្រូវបានកំណត់ដោយក្រសួងទទួលបន្ទុកវិស័យអប់រំ។

ឆ្នាំ១៩៩៥ ក្រសួងអប់រំ យុវជន និងកីឡា បានសហការជាមួយអង្គការសហប្រតិបត្តិការអន្តរជាតិកម្ពុជាបានចាប់ផ្តើមរៀបចំប្រព័ន្ធអក្ខរក្រមនៃភាសាជនជាតិដើមភាគតិចចំនួន៥ ក្នុងចំណោមភាសាទាំងអស់ប្រមាណ២៤ ភាសា ជាភាសាដែលគេនិយាយទូលំទូលាយច្រើន ហើយយកអក្ខរក្រមខ្មែរធ្វើជាគោល និងអនុម័តនៅឆ្នាំ២០០៣

ដើម្បីសម្របសម្រួលដល់ការរៀនរបស់សិស្សជនជាតិដើមភាគតិច ព្នង ទំពួន កាវ៉ែត គ្រឹង ព្រៅ និងគ្រឹង។ ក្នុងពេលជាមួយគ្នានេះដែរអង្គការសហប្រតិបត្តិការអន្តរជាតិកម្ពុជា បានបង្កើតកម្មវិធីអក្ខរកម្មពីរភាសាដែលរៀបចំឡើងសម្រាប់ការអប់រំក្រៅប្រព័ន្ធ ដោយផ្តោតលើអក្ខរកម្មមនុស្សពេញវ័យ។

ដោយប្រើប្រាស់ក្របខណ្ឌគតិយុត្ត និងបទពិសោធដែលទទួលបានពីដៃគូអភិវឌ្ឍនានា ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតគណៈកម្មការអប់រំពីរភាសា ដើម្បីរៀបចំគោលការណ៍ណែនាំលេខ ២៩៧២ អយក.បស ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១០ ស្តីពីការអនុវត្តកម្មវិធីអប់រំពីរភាសាសម្រាប់កុមារជនជាតិដើមភាគតិចនៅក្នុងខេត្តនៃតំបន់ខ្ពង់រាប និងប្រកាសលេខ ៤៨ អយក.ប្រក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៣ ស្តីពីការកំណត់ភាសាសម្រាប់អ្នកសិក្សាសញ្ជាតិខ្មែរ ដែលមានដើមកំណើតជាខ្មែរជនជាតិដើមភាគតិច។ ក្រសួងអប់រំ យុវជន និងកីឡា បានសហការជាមួយដៃគូអភិវឌ្ឍពាក់ព័ន្ធរៀបចំសៀវភៅសិក្សា និងគំរូអប់រំពីរភាសាពីថ្នាក់ទី១ ដល់ថ្នាក់ទី៣ នៅបឋមសិក្សា ដើម្បីផ្តល់ឱ្យកុមារជនជាតិដើមភាគតិចជាស្ពានសម្រាប់ឆ្លងទៅប្រើប្រាស់ភាសាជាតិ។

ឆ្នាំ២០០២ ក្រសួងអប់រំ យុវជន និងកីឡា បានសហការជាមួយអង្គការឃែរកម្ពុជា អនុវត្តសាកល្បងគម្រោងអប់រំកុមារតំបន់ខ្ពង់រាបនៅក្នុងខេត្តរតនគិរី។ ឆ្នាំ២០០៣ អង្គការឃែរកម្ពុជា បានអនុវត្តសាកល្បងកម្មវិធីអប់រំពីរភាសាក្នុងប្រព័ន្ធកម្រិតបឋមសិក្សានៅភូមិជនជាតិដើមភាគតិចទំពួន និងគ្រឹង ចំនួន ៦ភូមិ ក្នុងខេត្តរតនគិរី ហើយទទួលបានជោគជ័យដោយមានការគាំទ្រពីអង្គការយូនីសេហ្វ និងទីភ្នាក់ងារអូស្រ្តាលីដើម្បីអភិវឌ្ឍន៍អន្តរជាតិ(AusAID)។ ឆ្នាំ២០០៧ ក្រសួងអប់រំ យុវជន និងកីឡា បានសហការជាមួយអង្គការយូនីសេហ្វ អនុវត្តកម្មវិធីអប់រំពីរភាសានៅបឋមសិក្សា ដែលមានការគាំទ្របច្ចេកទេសពីអង្គការឃែរកម្ពុជានៅក្នុងខេត្តរតនគិរី និងពង្រីកវិសាលភាពដល់ខេត្តមណ្ឌលគិរី ស្ទឹងត្រែង និងចុងក្រោយនៅក្នុងខេត្តក្រចេះ។ ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៨ ក្រសួងអប់រំ យុវជន និងកីឡា បានអនុវត្តកម្មវិធីអប់រំពហុភាសា សម្រាប់បឋមសិក្សា កើនឡើងពី ៥៤សាលារៀន ដល់៨០សាលារៀន។

ឆ្នាំ២០០៩ អង្គការឃែរកម្ពុជា បានចាប់ផ្តើមអនុវត្តគម្រោងអប់រំពីរភាសាសាកល្បងនៅតាមសាលាមត្តេយ្យសិក្សាសហគមន៍។ នៅឆ្នាំ២០១១ នាយកដ្ឋានអប់រំកុមារតូច បានសហការជាមួយសហគមន៍ និងអាជ្ញាធរដែនដី ចាប់ផ្តើមអនុវត្តគម្រោងសាកល្បងរបស់ខ្លួនដោយបញ្ចូលមត្តេយ្យសិក្សាសហគមន៍២០កន្លែង នៅក្នុងខេត្តចំនួន៥ (ខេត្តរតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ក្រចេះ និង ខេត្តព្រះវិហារ) ជាមត្តេយ្យសិក្សាសហគមន៍អប់រំពហុភាសាដោយមានការគាំទ្រពីអង្គការយូនីសេហ្វ និងបច្ចេកទេសពីអង្គការឃែរកម្ពុជា។ ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៨ ក្រសួងអប់រំ យុវជន និងកីឡា បានអនុវត្តកម្មវិធីអប់រំពហុភាសាសម្រាប់មត្តេយ្យសិក្សាកើនឡើងពី ៣៤ថ្នាក់/មណ្ឌល ដល់៩៤ ថ្នាក់/មណ្ឌល។

ឆ្នាំ២០១៤ ក្រសួងអប់រំ យុវជន និងកីឡា បានកសាងផែនការសកម្មភាពជាតិស្តីពីការអប់រំពហុភាសា ២០១៥-២០១៨ ដោយបានដាក់ចេញនូវយុទ្ធសាស្រ្តសំខាន់៦ ដើម្បីធានាការផ្តល់សេវាអប់រំសម្រាប់កុមារជនជាតិដើមភាគតិច និងមានការវាយតម្លៃបញ្ចប់ការអនុវត្តផែនការនេះដោយបណ្ឌិត Jessica Ball និង Merriam Smith នៅចុងឆ្នាំ២០១៨។ លទ្ធផលនៃការវាយតម្លៃបានផ្តល់បទពិសោធ និងអនុសាសន៍ដែលជាធាតុចូលសម្រាប់អភិវឌ្ឍផែនការសកម្មភាពស្តីពីការអប់រំពហុភាសា ២០១៩-២០២៣ ឱ្យកាន់តែមានសក្តានុពលភាព។

ឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីការអប់រំ គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច និងផែនការយុទ្ធសាស្រ្តវិស័យអប់រំ២០១៩-២០២៣ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំផែនការសកម្មភាពស្តីពីការអប់រំពហុភាសា២០១៩-២០២៣ ដោយធ្វើចំណោលទៅលើការពង្រីកសេវាអប់រំពហុភាសាពី៥ភាសា ទៅ៦ភាសា រួមទាំងភាសាចារាយ។ ការពង្រីកសេវា

នេះនឹងធ្វើឱ្យមានគ្រូមត្តេយ្យសិក្សាសហគមន៍ និងមត្តេយ្យសិក្សារដ្ឋអប់រំពហុភាសាកើនឡើងពី ៩៤នាក់ ដល់១២៧នាក់ គ្រូបឋមសិក្សារួមទាំងគ្រូកិច្ចសន្យាអប់រំពហុភាសាកើនឡើងពី ១៩៧នាក់ ដល់២៥៣នាក់ និងគ្រូអក្ខរកម្មអប់រំពហុភាសាមាន ២១នាក់។ សិស្សមត្តេយ្យសិក្សាជនជាតិដើមភាគតិចកើនឡើងពី ១ ៧៩៨ នាក់ ដល់ ២ ៥៣១នាក់ សិស្សបឋមសិក្សាជនជាតិដើមភាគតិចកើនឡើងពី ៤ ៨៦៦នាក់ ដល់ ៥ ៨៩៩នាក់ និងសិស្សអក្ខរកម្មជនជាតិដើមភាគតិចមាន ៤២០នាក់ (ឧបសម្ព័ន្ធ១០.៧)។ ក្រសួងអប់រំ យុវជន និងកីឡា គ្រោងដាក់បញ្ចូលការបណ្ដុះបណ្ដាលគ្រូអប់រំពហុភាសានៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តស្ទឹងត្រែង ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្ដែងរបស់ខេត្តនៃតំបន់ខ្ពង់រាប ដែលធ្វើឱ្យកម្មវិធីអប់រំពហុភាសាប្រកបដោយគុណភាព និងនិរន្តរភាព។

## ១. ចក្ខុវិស័យ

ផែនការសកម្មភាពស្តីពីការអប់រំពហុភាសា ២០១៩-២០២៣ មានចក្ខុវិស័យធ្វើឱ្យជនជាតិដើមភាគតិច ទទួលបានការអប់រំតាមរយៈភាសាកំណើតដែលមានគុណភាព ប្រកបដោយបរិយាបន្ន សមធម៌ និងឱកាសសិក្សាពេញមួយជីវិត ដើម្បីក្លាយជាពលរដ្ឋពេញលេញ មានគុណតម្លៃ និងផលិតភាពក្នុងការចូលរួមអភិវឌ្ឍវប្បធម៌ សង្គម និងសេដ្ឋកិច្ចប្រកបដោយចីរភាព។

## ២. គោលបំណង

ផែនការសកម្មភាពស្តីពីការអប់រំពហុភាសា ២០១៩-២០២៣ មានគោលបំណងដើម្បីអភិវឌ្ឍវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទារបស់ជនជាតិដើមភាគតិចតាមរយៈកម្មវិធីអប់រំពហុភាសា ដែលនាំឱ្យមានការកើនឡើងនូវលទ្ធភាព និងលទ្ធផលសិក្សា ដោយមានការចូលរួមថែរក្សាភាសា និងវប្បធម៌របស់ជនជាតិដើមភាគតិច។

## ៣.វិសាលភាព

កម្មវិធីអប់រំពហុភាសាមានវិសាលភាពនៅកម្រិតមត្តេយ្យសិក្សា បឋមសិក្សា និងអប់រំក្រៅប្រព័ន្ធដែលអនុវត្តនៅខេត្តរតនគិរី មណ្ឌលគិរី ក្រចេះ ស្ទឹងត្រែង និងខេត្តព្រះវិហារ។ ភាសាកំណើតដែលបាន និងកំពុងអនុវត្តក្នុងកម្មវិធីអប់រំពហុភាសាមានភាសាព្នង ទំពួន ការ៉ែត គ្រឹង ព្រៅ និងកួយ។ ដោយឡែកភាសាចារាយស្ថិតក្នុងដំណាក់កាលរៀបចំ។

## ៤. គោលដៅ

១. ពង្រីកសេវាអប់រំពហុភាសាប្រកបដោយសមធម៌ បរិយាបន្ន និងមាននិរន្តរភាពដល់ជនជាតិដើមភាគតិច ជាពិសេសកុមារ

២. ពង្រឹងការអប់រំពហុភាសាឱ្យមានគុណភាពដោយផ្សារភ្ជាប់នឹងភាសាកំណើត វប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់របស់ជនជាតិដើមភាគតិច

៣. លើកកម្ពស់ការចូលរួមរបស់សហគមន៍ជនជាតិដើមភាគតិច និងកិច្ចសហប្រតិបត្តិការគ្រប់ភាគីពាក់ព័ន្ធ។

## ៥. យុទ្ធសាស្ត្រ

យុទ្ធសាស្ត្រ១៖ ផ្តល់ការគាំទ្របន្ថែមដល់ការអនុវត្ត និងពង្រីកកម្មវិធីអប់រំពហុភាសាដល់កុមារា កុមារី និងយុវជនក្រៅសាលារៀនជាជនជាតិដើមភាគតិច

យុទ្ធសាស្ត្រ២៖ លើកកម្ពស់សមត្ថភាពស្ថាប័នពាក់ព័ន្ធ និងអភិវឌ្ឍធនធានមនុស្សក្នុងការផ្តល់សេវាអប់រំពហុភាសាប្រកបដោយគុណភាព

យុទ្ធសាស្ត្រ៣៖ អភិវឌ្ឍកម្មវិធីសិក្សាអប់រំពហុភាសា និងសម្ភារសិក្សាដោយផ្សារភ្ជាប់នឹងវប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់របស់ជនជាតិដើមភាគតិច

យុទ្ធសាស្ត្រ៤៖ អភិវឌ្ឍ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធ សម្ភារសិក្សារូបវន្ត និងបរិស្ថានសាលារៀន

យុទ្ធសាស្ត្រ៥៖ ធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធព័ត៌មានគ្រប់គ្រងកម្មវិធីអប់រំពហុភាសា

យុទ្ធសាស្ត្រ៦៖ បង្កើនការចូលរួមរបស់ឪពុកម្តាយ សហគមន៍ជនជាតិដើមភាគតិច និងកិច្ចសហការជាមួយភាគីពាក់ព័ន្ធ ដើម្បីអនុវត្តកម្មវិធីអប់រំពហុភាសា

យុទ្ធសាស្ត្រ៧៖ ពង្រឹងយន្តការពិនិត្យតាមដាន និងវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស និងគុណភាពបង្រៀន និងរៀន។

## ៦.ផែនការសកម្មភាព

| យុទ្ធសាស្ត្រ / យុទ្ធសាស្ត្ររង | សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា(ឆ្នាំ) 1 | 2 | 3 | 4 | 5 | អង្គភាពទទួលខុសត្រូវចម្បង | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា(USD) | ការពិនិត្យតាមដាន និងវាយតម្លៃ | ប្រភពសម្រាប់ផ្ទៀងផ្ទាត់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| គោលដៅ១៖ **ពង្រីកសេវាអប់រំពហុភាសាប្រកបដោយសមធម៌ បរិយាបន្ន និងមាននិរន្តរភាពដល់ជនជាតិដើមភាគតិចជាពិសេសកុមារ** | | | | | | | | | | | | | | |
| ៥.១ យុទ្ធសាស្ត្រ១៖ ផ្តល់ការគាំទ្របន្ថែមដល់ការអនុវត្ត និងពង្រីកកម្មវិធីអប់រំពហុភាសាដល់កុមារា កុមារី និងយុវជនក្រៅសាលារៀនជាជនជាតិដើមភាគតិច | | | | | | | | | | | | | | |
| ៥.១.១ រៀបចំធ្វើយុទ្ធនាការប្រមូលកុមារចូលរៀន និងផ្សព្វផ្សាយពីសារៈសំខាន់នៃការអប់រំដល់ឪពុកម្តាយ និងសហគមន៍ | ៥.១.១.១ ធ្វើបច្ចុប្បន្នភាពគណៈកម្មការគ្រប់គ្រងសាលារៀន ដែលអនុវត្តកម្មវិធីអប់រំពហុភាសាដោយមានសមាសភាពជាជនជាតិដើមភាគតិច | ភាគរយនៃគណៈកម្មការគ្រប់គ្រងសាលារៀនត្រូវបានធ្វើបច្ចុប្បន្នភាព | ១០០% ជារៀងរាល់ឆ្នាំ | x | x | x | x | x | -សាលារៀន<br>-ការិ.អយក<br>-មន្ទីរអយក | -នា.បស<br>-នា.អកត<br>-នា.អកប<br>-នា.អពស<br>-ក្រុមប្រឹក្សាឃុំ/សង្កាត់ | | 0 | -មន្ទីរអយក<br>-ការិ.អយក<br>-ក្រុមប្រឹក្សាឃុំ/សង្កាត់<br>-នា.អពស | របាយការណ៍<br>ការិ.អយក<br>មន្ទីរអយក |
| | ៥.១.១.២ ធ្វើបច្ចុប្បន្នភាពផែនទីសិក្សា និងផែនទីខ្នងផ្ទះដែលមានកុមារដល់អាយុចូលរៀន និងអនក្ខរជនពេញវ័យជាជនជាតិដើមភាគតិច | ភាគរយនៃសាលារៀនដែលអនុវត្តកម្មវិធីអប់រំពហុភាសាបានធ្វើបច្ចុប្បភាពផែនទីសិក្សា និងផែនទីខ្នងផ្ទះ | ១០០% រយៈពេល៥ឆ្នាំ | x | x | x | x | x | -សាលារៀន<br>-ការិ.អយក<br>-មន្ទីរអយក<br>-ក្រុមប្រឹក្សាឃុំ/សង្កាត់<br>-សហគមន៍ | -នា.បស<br>-នា.អកត<br>-នា.អកប<br>-នា.អពស<br>-ដៃគូអភិវឌ្ឍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ២០ ០០០ | -ការិ.អយក<br>-មន្ទីរអយក<br>-ក្រុមប្រឹក្សាឃុំ/សង្កាត់<br>-សាលារៀន | របាយការណ៍<br>ការិ.អយក<br>មន្ទីរអយក<br>សាលារៀន |
| | ៥.១.១.៣ កៀរគរ និងចលនាឪពុកម្តាយ សហគមន៍ ឱ្យចូលរួមក្នុងយុទ្ធនាការប្រមូលកុមារ និងជនពេញវ័យជាជនជាតិដើមភាគតិចចូលរៀន | ចំនួនតំណាងឪពុកម្តាយ អាណាព្យាបាល សហគមន៍ និងកុមារជនជាតិដើមភាគតិចចូលរួមធ្វើយុទ្ធនាការ | យ៉ាងតិច១០គ្រួសារក្នុងមួយសាលារៀនដែលអនុវត្តកម្មវិធីអប់រំពហុភាសា(ជារៀងរាល់ឆ្នាំ) | x | x | x | x | x | -សាលារៀន<br>-ការិ.អយក<br>-មន្ទីរអយក<br>-ក្រុមប្រឹក្សាឃុំ/សង្កាត់<br>-សហគមន៍ | -នា.បស<br>-នា.អកប<br>-នា.អកត<br>-នា.អពស<br>-ដៃគូអភិវឌ្ឍ | | 0 | -មន្ទីរអយក<br>-ការិ.អយក<br>-សាលារៀន | របាយការណ៍<br>ការិ.អយក<br>មន្ទីរអយក |

## ៦.ផែនការសកម្មភាព

| យុទ្ធសាស្ត្រ / យុទ្ធសាស្ត្ររង | សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា(ឆ្នាំ) | | | | | អង្គភាពទទួលខុសត្រូវចម្បង | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា(USD) | ការពិនិត្យតាមដាន និងវាយតម្លៃ | ប្រភពសម្រាប់ផ្ទៀងផ្ទាត់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | 1 | 2 | 3 | 4 | 5 | | | | | | |
| | ៥.១.១.៤ បើកយុទ្ធនាការប្រមូលកុមារចូលរៀនពិសេសកុមារជនជាតិដើមភាគតិច | ភាគរយនៃសាលារៀនដែលអនុវត្តកម្មវិធីអប់រំពហុភាសាបានធ្វើយុទ្ធនាការប្រមូលកុមារចូលរៀន និងមានជនជាតិដើមភាគតិចចូលរួម | ១០០% ជារៀងរាល់ឆ្នាំ | x | x | x | x | x | -សាលារៀន<br>-ការិ.អយក<br>-មន្ទីរអយក<br>-អាជ្ញាធរដែនដី<br>-ក្រុមប្រឹក្សាស្រុក និងឃុំ | -នា.បស<br>-នា.អកត<br>-នា.អកប<br>-នា.អពស<br>-ដៃគូអភិវឌ្ឍ<br>-សហគមន៍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ<br>-សប្បុរសជន | ៤០ ០០០ | -មន្ទីរអយក<br>-ការិ.អយក<br>-សាលារៀន | របាយការណ៍សាលារៀន ការិ.អយក មន្ទីរអយក |
| | ៥.១.១.៥ ផលិតសម្ភារសម្រាប់ផ្សព្វផ្សាយ ស្តីពីការចូលរៀន និងសារៈសំខាន់នៃការអប់រំតាមរយៈវីដេអូ សារសម្លេង ផ្ទាំងរូបភាពធំ ខិត្តប័ណ្ណ (ភាសាខ្មែរ និងភាសាកំណើត) | ចំនួនប្រភេទសម្ភារផ្សព្វផ្សាយដែលបានផលិតសម្រាប់ការអប់រំពហុភាសាកម្រិតមត្តេយ្យ បឋមសិក្សា និងអប់រំក្រៅប្រព័ន្ធ | សម្ភារ៣ប្រភេទផ្សេងគ្នាក្នុងរយៈពេល៤ឆ្នាំ | | x | x | x | x | -នា.អពស<br>-នា.អកប<br>-នា.បស<br>-នា.អកត<br>-នា.បវព | -មន្ទីរអយក<br>-ការិ.អយក<br>-សាលារៀន<br>-សហគមន៍<br>-ដៃគូអភិវឌ្ឍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ១០០ ០០០ | -នា.អពស<br>-នា.អកប | របាយការណ៍ ឯកសារផ្សេងៗដែលបានផលិត |
| | ៥.១.១.៦ ផ្សព្វផ្សាយ និងអំពាវនាវ ស្តីពីសារៈសំខាន់នៃការសិក្សាដល់ឪពុកម្តាយ និងសហគមន៍ជាទៀងទាត់ ( ជាពិសេសមុនរដូវធ្វើចម្ការ ឬប្រមូលផលនានា ) | ចំនួនមន្ទីរអយកដែលបានធ្វើការផ្សព្វផ្សាយ | ៥ រយៈពេល៤ឆ្នាំ | | x | x | x | x | -មន្ទីរអយក<br>-ការិ.អយក<br>-សាលារៀន<br>-ក្រុមប្រឹក្សាឃុំ/សង្កាត់<br>-សហគមន៍ | -នា.បស<br>-នា.អកត<br>-នា.អកប<br>-នា.អពស<br>-នា.បវព<br>-ដៃគូអភិវឌ្ឍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ៦០ ០០០ | -មន្ទីរអយក<br>-ការិ.អយក<br>-នា.អពស<br>-នា.អកប | របាយការណ៍ មន្ទីរអយក នា.អពស នា.អកប |

## ៦.ផែនការសកម្មភាព

| យុទ្ធសាស្ត្រ / យុទ្ធសាស្ត្ររង | សកម្មភាព | សូចនាករ | ចំណុចដៅ | គ្របខណ្ឌពេលវេលា(ឆ្នាំ) | | | | | អង្គភាពទទួលខុសត្រូវចម្បង | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា(USD) | ការពិនិត្យតាមដាន និងវាយតម្លៃ | ប្រភពសម្រាប់ផ្ទៀងផ្ទាត់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | 1 | 2 | 3 | 4 | 5 | | | | | | |
| ៥.១.២ ពង្រីកកម្មវិធីអប់រំពហុភាសាទៅតំបន់ដែលមានកុមារ និងជនពេញវ័យជាជនជាតិដើមភាគតិច | ៥.១.២.១ សិក្សាពីស្ថានភាពដើម្បីបើកថ្នាក់អប់រំពហុភាសាថ្មី រួមទាំងថ្នាក់អប់រំពហុភាសាចារាយនៅតាមសាលាបឋមសិក្សាសាធារណៈ មត្តេយ្យសិក្សាសហគមន៍ និងថ្នាក់អក្ខរកម្មដែលជាតំបន់មានជនជាតិដើមភាគតិច រួមទាំងតំបន់ជនជាតិដើមភាគតិចចារាយ | ចំនួនថ្នាក់/មណ្ឌលអប់រំពហុភាសាដែលបានបង្កើតថ្មីនៅក្នុងខេត្តទាំង៥ រួមទាំងថ្នាក់/មណ្ឌលជនជាតិដើមភាគតិចចារាយ | មតស (៣៣)<br>បស (៥៦)<br>អកប (២១) | x | x | x | x | x | -មន្ទីរអយក<br>-ការិ.អយក<br>-សាលារៀន<br>-គ.ស.អ<br>-ក្រុមប្រឹក្សាឃុំ/សង្កាត់ | -នា.អពស<br>-នា.បស<br>-នា.អកត<br>-នា.អកប<br>-ដៃគូអភិវឌ្ឍ<br>-សហគមន៍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ១០០ ០០០ | -មន្ទីរអយក<br>-ការិ.អយក | របាយការណ៍<br>មន្ទីរអយក<br>នា.អពស<br>នា.អកប<br>គ.ស.អ |
| | ៥.១.២.២ សិក្សាពីស្ថានភាព និងទីតាំងដែលត្រូវអនុវត្តកម្មវិធីអប់រំពហុភាសាជាភាសាចារាយ | ចំនួនស្រុកដែលបានវិភាគស្ថានភាពដើម្បីអនុវត្តកម្មវិធីអប់រំពហុភាសាជាភាសាចារាយ | ២ | | x | x | x | x | -មន្ទីរអយក<br>-ការិ.អយក<br>-ក្រុមប្រឹក្សាឃុំ/សង្កាត់<br>-ដៃគូអភិវឌ្ឍ | -នា.អពស<br>-នា.បស<br>-នា.អកត<br>-នា.អកប<br>-សហគមន៍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ១០ ០០០ | -មន្ទីរអយក<br>-ការិ.អយក | របាយការណ៍<br>មន្ទីរអយក |
| | ៥.១.២.៣ សិក្សា និងបង្កើតអក្ខរក្រមភាសាចារាយ | ចំនួនភាសាជនជាតិដើមភាគតិចត្រូវបានអនុម័តឱ្យប្រើប្រាស់ | ១ | x | x | x | | | -ក្រសួងអយក<br>-នា.អពស<br>-នា.អកប<br>-នា.គនប<br>-រាជបណ្ឌិតសភា<br>-មន្ទីរអយក<br>-ការិ.អយក<br>-ដៃគូអភិវឌ្ឍ | -នា. អកស<br>-នា.បស<br>-នា.អកត<br>-សហគមន៍<br>-សាកលវិទ្យាល័យ<br>-គ.ស.អ<br>-ដៃគូអភិវឌ្ឍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ១៥០ ០០០ | -នា.អពស<br>-មន្ទីរអយក<br>-ការិ.អយក | របាយការណ៍ និងឯកសារភាសាចារាយ<br>នា.អពស<br>នា.អកប |

## ៦.ផែនការសកម្មភាព

| យុទ្ធសាស្ត្រ / យុទ្ធសាស្ត្ររង | សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា(ឆ្នាំ) | | | | | អង្គភាពទទួលខុសត្រូវចម្បង | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា(USD) | ការពិនិត្យតាមដាន និងវាយតម្លៃ | ប្រភពសម្រាប់ផ្ទៀងផ្ទាត់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | 1 | 2 | 3 | 4 | 5 | | | | | | |
| | ៥.១.២.៤ បញ្ចូលភាសាចារាយក្នុងកម្មវិធីអប់រំពហុភាសាកម្រិតមត្តេយ្យសិក្សា បឋមសិក្សា និងអប់រំក្រៅប្រព័ន្ធ | -ចំនួនភាសាថ្មីដែលបានដាក់បញ្ចូលក្នុងកម្មវិធីអប់រំពហុភាសា | ១ | x | x | x | x | x | -មន្ទីរអយក<br>-ការិ.អយក<br>-នា.អពស<br>-នា.អកប | -នា.បស<br>-នា.អកត<br>-ដៃគូអភិវឌ្ឍ<br>-សហគមន៍ | | 0 | -នា.អពស<br>-នា.អកប | របាយការណ៍<br>មន្ទីរអយក<br>នា.អពស<br>នា.អកប |
| | ៥.១.២.៥ ជ្រើសរើសគ្រូអប់រំពហុភាសាថ្មីជាជនជាតិដើមភាគតិច រួមទាំងជនជាតិដើមភាគតិចចារាយ | ចំនួនគ្រូអប់រំពហុភាសាថ្មី រួមទាំងគ្រូអប់រំពហុភាសាចារាយដែលបានជ្រើសរើសក្នុងខេត្តទាំង៥ | មតស (៣៣)<br>បស (៥៦)<br>អកប (២១) | x | x | x | x | x | -មន្ទីរអយក<br>-ការិ.អយក<br>-សាលារៀន<br>-ក្រុមប្រឹក្សាឃុំ/សង្កាត់ | -នា.បស<br>-នា.អកប<br>-នា.អកត<br>-នា.អពស<br>-អាជ្ញាធរដែនដី | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ២៥ ០០០ | -មន្ទីរអយក<br>-ការិ.អយក<br>-នា.អពស | របាយការណ៍<br>មន្ទីរអយក<br>នា. អពស<br>នា.អកប<br>ការិ.អយក |
| | ៥.១.២.៦ ចុះឈ្មោះសិស្សអប់រំពហុភាសាថ្មី រួមទាំងសិស្សជនជាតិដើមភាគតិចចារាយចូលរៀនក្នុងថ្នាក់អប់រំពហុភាសាក្នុងខេត្តនៃតំបន់ខ្ពង់រាបភាគឦសានទាំង៥ | ចំនួនសិស្សអប់រំពហុភាសាថ្មី រួមទាំងសិស្សជនជាតិដើមភាគតិចចារាយបានចុះឈ្មោះចូលរៀនក្នុងថ្នាក់អប់រំពហុភាសានៃខេត្តទាំង៥ | មតស(៧៣៣)<br>បស (១០៣៣)<br>អកប (៤២០)<br>(រយៈពេល៥ឆ្នាំ) | x | x | x | x | x | -គណៈកម្មការគ្រប់គ្រងសាលារៀន<br>-ការិ.អយក<br>-មន្ទីរអយក<br>-ក្រុមប្រឹក្សាឃុំ/សង្កាត់ | -នា.អពស<br>-នា.អកប<br>-នា.បស<br>-នា.អកត<br>-សហគមន៍<br>-អាជ្ញាធរដែនដី | | 0 | -មន្ទីរអយក<br>-ការិ.អយក<br>-នា.អពស<br>-នា.អកប | របាយការណ៍<br>សាលារៀន<br>មន្ទីរអយក<br>ការិ.អយក |

## ៦.ផែនការសកម្មភាព

| យុទ្ធសាស្ត្រ / យុទ្ធសាស្ត្ររង | សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា(ឆ្នាំ) | | | | | អង្គភាពទទួលខុសត្រូវចម្បង | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា(USD) | ការពិនិត្យតាមដាន និងវាយតម្លៃ | ប្រភពសម្រាប់ផ្ទៀងផ្ទាត់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | 1 | 2 | 3 | 4 | 5 | | | | | | |
| | ៥.១.២.៧ រៀបចំផែនការប្រតិទិនសិក្សាតាមស្ថានភាពជាក់ស្តែងរបស់សហគមន៍ | ចំនួនស្រុកអនុវត្តកម្មវិធីអប់រំពហុភាសាដែលបានរៀបចំផែនការប្រតិទិនសិក្សា | ១ស្រុក (ខេត្តស្ទឹងត្រែង) | x | x | x | x | | -សាលារៀន<br>-ការិ.អយក<br>-មន្ទីរអយក<br>-អាជ្ញាធរ<br>-ក្រុមប្រឹក្សាឃុំ/សង្កាត់<br>-សហគមន៍ | -នា.អពស<br>-នា.បស<br>-នា.អកត<br>-នា. អកប<br>-ដៃគូអភិវឌ្ឍ | | 0 | -មន្ទីរអយក<br>-ការិ.អយក | របាយការណ៍<br>ការិ.អយក<br>មន្ទីរអយក |
| ៥.១.៣ ផ្តល់អាហារូបត្ថម្ភ និងសេវាសុខភាពអនាម័យ (ចំណីអាហារ ទឹកស្អាត និងកម្មវិធីសុខភាពផ្សេងៗ) តាមសាលារៀនអប់រំពហុភាសា | ៥.១.៣.១ ផ្តល់អណ្តូងទឹក បង្គន់អនាម័យ កន្លែងលាងដៃ ឬទឹកស្អាត ដល់សាលារៀនដែលអនុវត្តកម្មវិធីអប់រំពហុភាសា មិនទាន់មាន | ចំនួនសាលាបឋមសិក្សាសាធារណៈដែលបានទទួល | ២០សាលារៀន (រយៈពេល៥ឆ្នាំ) | x | x | x | x | x | -មន្ទីរអយក<br>-ការិ.អយក<br>-សាលារៀន<br>-នា.សស | -នា.បស<br>-នា.អកត<br>-នា.អកប<br>-នា. អពស<br>-ដៃគូអភិវឌ្ឍ<br>-សហគមន៍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ<br>-សប្បុរសជន | ៩៥ 000 | -មន្ទីរអយក<br>-នា.សស<br>-នា. អពស | របាយការណ៍<br>មន្ទីរអយក<br>ការិ.អយក<br>នា.សស |
| | ៥.១.៣.២ ផ្សព្វផ្សាយស្តីពីការអប់រំសុខភាព អនាម័យ និងសុវត្ថិភាពចំណីអាហារដល់សិស្ស គ្រូ នៅសាលាដែលអនុវត្តកម្មវិធីអប់រំពហុភាសា និងសហគមន៍ជនជាតិដើមភាគតិច | ភាគរយសាលាដែលអនុវត្តកម្មវិធីអប់រំពហុភាសាបានទទួលការផ្សព្វផ្សាយ | មតស៥0%<br>បស១00%<br>អកប ១00% | x | x | x | x | x | -នា.សស<br>-មន្ទីរអយក<br>-ការិ.អយក<br>-សាលារៀន | -នា.អពស<br>-នា.អកត<br>-នា.បស<br>-នា.អកប<br>-សាលារៀន<br>-សហគមន៍<br>-ដៃគូអភិវឌ្ឍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ<br>-សប្បុរសជន | ៨0 000 | -នា.សស<br>-នា.ធគអ<br>-មន្ទីរអយក | របាយការណ៍<br>ការិ.អយក<br>មន្ទីរអយក<br>នា.សស |

## ៦.ផែនការសកម្មភាព

| យុទ្ធសាស្ត្រ / យុទ្ធសាស្ត្ររង | សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា(ឆ្នាំ) | | | | | អង្គភាពទទួលខុសត្រូវចម្បង | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា(USD) | ការពិនិត្យតាមដាន និងវាយតម្លៃ | ប្រភពសម្រាប់ផ្ទៀងផ្ទាត់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | 1 | 2 | 3 | 4 | 5 | | | | | | |
| ៥.១.៤ ផ្តល់អាហារូបករណ៍ និងអន្តេវាសិកដ្ឋានដល់សិស្សជនជាតិដើមភាគតិច ដែលងាយរងគ្រោះ ជាពិសេសសិស្សស្រី (សម្ភារសិក្សា មធ្យោបាយធ្វើដំណើរ សម្លៀកបំពាក់...) | ៥.១.៤.១ ជ្រើសរើសសិស្សអាហារូបករណ៍ក្រីក្រជាជនជាតិដើមភាគតិចកម្រិតបឋមសិក្សាជាពិសេសសិស្សស្រី | ចំនួនសិស្សជនជាតិដើមភាគតិច បានទទួលអាហារូបករណ៍ពីថ្នាក់ទី១ដល់ទី៦ | ២០១៩= ២៤៤៦នាក់ ២០២០-២០២៣= ២៦៨០នាក់ ក្នុង១ឆ្នាំ | x | x | x | x | x | -នា.បស<br>-មន្ទីរអយក<br>-ការិ.អយក<br>-សាលារៀន | -នា.អពស<br>-អាជ្ញាធរដែនដី<br>-ក្រុមប្រឹក្សាឃុំ/សង្កាត់<br>-ដៃគូអភិវឌ្ឍ<br>-សហគមន៍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ<br>-សប្បុរសជន | ៧៩០ ០០០ | -មន្ទីរអយក<br>-ការិ.អយក<br>-នា.បស | របាយការណ៍ មន្ទីរអយក ការិ.អយក នា.បស |
| | ៥.១.៤.២ ជ្រើសរើសសិស្សអាហារូបករណ៍ក្រីក្រជាជនជាតិដើមភាគតិច កម្រិតមធ្យមសិក្សាទុតិយភូមិពិសេសសិស្សស្រី | ចំនួនសិស្សជនជាតិដើមភាគតិច បានទទួលអាហារូបករណ៍មធ្យមសិក្សាទុតិយភូមិ | ២០១៩= ១០៥៦នាក់ ២០២០-២០២៣= ២២៥៥នាក់ (រយៈពេល៤ឆ្នាំ) | x | x | x | x | x | -នា.មចទ<br>-មន្ទីរអយក<br>-ការិ.អយក<br>-សាលារៀន | -នា.អពស<br>-ដៃគូអភិវឌ្ឍ<br>-អាជ្ញាធរដែនដី<br>-សហគមន៍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ<br>-សប្បុរសជន | ៤៩៦ ៦៥០ | -មន្ទីរអយក<br>-នា.មចទ<br>-ដៃគូអភិវឌ្ឍ | របាយការណ៍ ផ្តល់អាហារូបករណ៍ មន្ទីរអយក នា.មចទ ដៃគូអភិវឌ្ឍ |
| | ៥.១.៤.៣ ជ្រើសរើសសិស្សជនជាតិដើមភាគតិចនៅកម្រិតមធ្យមសិក្សាបឋមភូមិ ដែលក្រីក្រ និងនៅឆ្ងាយពីសាលារៀនជាពិសេសសិស្សស្រីត្រូវបានស្នាក់នៅអន្តេវាសិកដ្ឋាន | ចំនួនសិស្សជនជាតិដើមភាគតិចត្រូវបានស្នាក់នៅអន្តេវាសិកដ្ឋាន | ៦០នាក់ រយៈពេល៣ឆ្នាំ | x | x | x | | | -នា.មចទ<br>-មន្ទីរអយក<br>-ការិ.អយក<br>-សាលារៀន<br>-ដៃគូអភិវឌ្ឍ | -ដៃគូអភិវឌ្ឍ<br>-សហគមន៍<br>-អាជ្ញាធរដែនដី<br>-នា.អពស | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ<br>-សប្បុរសជន | ១៨ ៤៨០ | -មន្ទីរអយក<br>-នា.មចទ<br>-ដៃគូអភិវឌ្ឍ | របាយការណ៍ មន្ទីរអយក នា.មចទ ដៃគូអភិវឌ្ឍ |

## ៦.ផែនការសកម្មភាព

| យុទ្ធសាស្ត្រ / យុទ្ធសាស្ត្ររង | សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា(ឆ្នាំ) 1 | 2 | 3 | 4 | 5 | អង្គភាពទទួលខុសត្រូវចម្បង | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា(USD) | ការពិនិត្យតាមដាន និងវាយតម្លៃ | ប្រភពសម្រាប់ផ្ទៀងផ្ទាត់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ៥.១.៤.៤ ផ្តល់អាហារូបករណ៍ដល់គរុសិស្សងាយរងគ្រោះជាជនជាតិដើមភាគតិចពិសេសគរុសិស្សជានារី | ចំនួនគរុសិស្សជនជាតិដើមភាគតិចដែលបានទទួលអាហារូបករណ៍ | ៤០០នាក់រយៈពេល៥ឆ្នាំ | x | x | x | x | x | -មគភ.សគ<br>-សគវខ.ក្រច<br>-សគវខ.ពហ<br>-សគមម<br>-នា.បវ<br>-មន្ទីរអយក | -ដៃគូអភិវឌ្ឍ<br>-អាជ្ញាធរដែនដី<br>-នា.អពស<br>-សហគមន៍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ<br>-សប្បុរសជន | ៧៥ ០០០ | -នា.បវ<br>-នា.អពស | របាយការណ៍<br>នា.បវ<br>មន្ទីរអយក<br>សគមម |
| ៥.២ យុទ្ធសាស្ត្រ២៖ លើកកម្ពស់សមត្ថភាពស្ថាប័នពាក់ព័ន្ធ និងអភិវឌ្ឍធនធានមនុស្ស ក្នុងការផ្តល់សេវាអប់រំពហុភាសាប្រកបដោយគុណភាព | | | | | | | | | | | | | | |
| ៥.២.១ អភិវឌ្ឍលិខិតបទដ្ឋានគតិយុត្ត និងយន្តការការងារ | ៥.២.១.១ រៀបចំពិនិត្យ និងកែលម្អលិខិតបទដ្ឋានគតិយុត្តសម្រាប់អនុវត្តការអប់រំពហុភាសា | ចំនួនសេចក្តីណែនាំ | ១ | | x | x | | | -នា.អពស<br>-នា.អកប<br>-នា.អកស<br>-នា.គនប | -នា.បស<br>-នា.អកត<br>-នា.បល<br>-មន្ទីរអយក | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ១២ ០០០ | នា.អពស<br>នា.អកប | របាយការណ៍<br>នា.អពស<br>នា.អកប |
| | ៥.២.១.២ បន្ស៊ីការអប់រំពហុភាសាពីមត្តេយ្យសិក្សាទៅបឋមសិក្សា | ភាគរយសាលារៀនដែលត្រូវបានបន្ស៊ីការអប់រំពហុភាសាពីមត្តេយ្យសិក្សាទៅបឋមសិក្សា | ១០០% | x | x | x | x | x | -សាលារៀន<br>-ការិ.អយក<br>-មន្ទីរអយក | -នា.អពស<br>-នា.អកត<br>-នា.បស<br>-ដៃគូអភិវឌ្ឍ | | 0 | -មន្ទីរអយក<br>-ការិ.អយក<br>-នា.អពស | របាយការណ៍<br>មន្ទីរអយក<br>ការិ.អយក<br>សាលារៀន |
| | ៥.២.១.៣ សិក្សា និងបង្កើនមត្តេយ្យសិក្សាសហគមន៍សម្រេចបានតាមស្តង់ដាអប្បបរមា (គ្រូបង្រៀនថ្នាក់មត្តេយ្យសិក្សាសហគមន៍ស្តង់ដាអប្បបរមា) | ចំនួនថ្នាក់/មណ្ឌលមត្តេយ្យសិក្សាសហគមន៍សម្រេចបានតាមស្តង់ដាអប្បបរមា | ២៥ថ្នាក់/មណ្ឌល (គ្រូ ២៥នាក់) | x | x | x | x | x | -នា.អកត<br>-ក.ស.អ<br>-មន្ទីរអយក<br>-ការិ.អយក<br>-សាលារៀន<br>-ក្រុមប្រឹក្សាឃុំ/សង្កាត់ | -នា.អពស<br>-នា.ធគអ<br>-សហគមន៍<br>-ដៃគូអភិវឌ្ឍ | | ៣០ ០០០ | -នា.អពស<br>-នា.អកត<br>-មន្ទីរអយក<br>-ការិ.អយក | របាយការណ៍<br>មន្ទីរអយក<br>ការិ.អយក<br>នា.អកត |

## ៦.ផែនការសកម្មភាព

| យុទ្ធសាស្ត្រ / យុទ្ធសាស្ត្ររង | សកម្មភាព | សូចនាករ | ចំណុចដៅ | គ្របខណ្ឌពេលវេលា(ឆ្នាំ) | | | | | អង្គភាពទទួលខុសត្រូវចម្បង | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា(USD) | ការពិនិត្យតាមដាន និងវាយតម្លៃ | ប្រភពសម្រាប់ផ្ទៀងផ្ទាត់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | 1 | 2 | 3 | 4 | 5 | | | | | | |
| | ៥.២.១.៤ ពង្រាយគរុសិស្សដែលបានទទួលការបណ្តុះបណ្តាលបន្ថែមស្តីពីការអប់រំពហុភាសានៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តស្ទឹងត្រែងទៅកាន់សាលាអប់រំពហុភាសាត្រូវតាមភាសាកំណើត និងមានសមធម៌យេនឌ័រ | ចំនួនគរុសិស្សជនជាតិដើមភាគតិចដែលបានពង្រាយទៅកាន់សាលាអប់រំពហុភាសាត្រូវតាមភាសាកំណើត និងមានសមធម៌យេនឌ័រ | ៤០នាក់ | | | | x | x | -មន្ទីរអយក<br>-ការិ.អយក<br>-នា.បល<br>-នា.បវ<br>-មគភ.សត | -នា.អពស<br>-នា.បស<br>-ដៃគូអភិវឌ្ឍ | | 0 | -នា.បល<br>-នា.បវ<br>-មន្ទីរអយក<br>-ការិ.អយក | របាយការណ៍<br>មន្ទីរអយក<br>ការិ.អយក<br>នា.បវ<br>មគភ.សត |
| ៥.២.២ ពង្រឹងសមត្ថភាពដល់ស្ថាប័នពាក់ព័ន្ធក្នុងការផ្តល់សេវាអប់រំពហុភាសា | ៥.២.២.១ បង្កើតផ្នែកឬបញ្ចូលកម្មវិធីអប់រំពហុភាសា ទៅក្នុងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តស្ទឹងត្រែង | ចំនួនផ្នែក ឬបញ្ចូលកម្មវិធីអប់រំពហុភាសាទៅក្នុងមជ្ឈ.គរុកោសល្យភូមិភាគស្ទឹងត្រែង | ១ | | x | x | | | -នា.បវ<br>-មគភ.សត<br>-មន្ទីរអយក<br>-នា.អពស | -នា.អកប<br>-នា.អកស<br>-ដៃគូអភិវឌ្ឍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ៤០ 000 | -នា.បវ<br>-នា.អពស | របាយការណ៍<br>មគភ.សត<br>នា.អពស<br>នា.បវ |
| | ៥.២.២.២ សិក្សាពីការបង្កើតមណ្ឌលធនធានសម្រាប់សិក្សាស្រាវជ្រាវ និងរក្សាឯកសារ ធនធាន វប្បធម៌ ប្រពៃណីរបស់សហគមន៍ជនជាតិដើមភាគតិច | ចំនួនមណ្ឌលធនធានសម្រាប់តម្កល់ឯកសារភាសាជនជាតិដើមភាគតិច | ១ | | | | x | x | -នា.គនប<br>-មន្ទីរអយក<br>-នា.សំណង់<br>-នា.អពស<br>-ដៃគូអភិវឌ្ឍ | -នា. អកប<br>-នា.បវ<br>-សប្បុរសជន<br>-សហគមន៍<br>-ក.ស.អ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ<br>-សប្បុរសជន | ១៥ 000 | -នា.អពស<br>-នា.សំណង់<br>-នា.គនប | របាយការណ៍<br>សិក្សា<br>មណ្ឌលធនធាន |

## ៦.ផែនការសកម្មភាព

| យុទ្ធសាស្ត្រ / យុទ្ធសាស្ត្ររង | សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា(ឆ្នាំ) 1 | 2 | 3 | 4 | 5 | អង្គភាពទទួលខុសត្រូវចម្បង | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា(USD) | ការពិនិត្យតាមដាន និងវាយតម្លៃ | ប្រភពសម្រាប់ផ្ទៀងផ្ទាត់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ៥.២.២.៣ ជ្រើសរើសមន្ត្រីអប់រំដែលមានដើមកំណើតជាជនជាតិដើមភាគតិចសម្រាប់បំរើការនៅក្រសួងអយក មន្ទីរអយក និងការិ.អយក | ចំនួនមន្ត្រីអប់រំដែលមានដើមកំណើតជាជនជាតិដើមភាគតិច | ១២នាក់ រយៈពេល៥ឆ្នាំ | x | x | x | x | x | -មន្ទីរអយក<br>-ការិ.អយក<br>-នា.បល<br>-នា.អពស | -នា.អកត<br>-នា.បស<br>-នា.អកប<br>-ដៃគូអភិវឌ្ឍ | | 0 | -នា.អពស<br>-មន្ទីរអយក | របាយការណ៍<br>មន្ទីរអយក<br>ការិ.អយក<br>នា.អពស<br>នា.អកប |
| | ៥.២.២.៤ កសាងសមត្ថភាពមន្ត្រីក្រសួងអយក មន្ទីរអយក ការិ.អយក សាលារៀន ស្ថាប័នពាក់ព័ន្ធ និងតំណាងសហគមន៍ជនជាតិដើមភាគតិចដើម្បីអនុវត្តកម្មវិធីអប់រំពហុភាសា | ចំនួនមន្ត្រីអប់រំ និងអ្នកពាក់ព័ន្ធដែលបានកសាងសមត្ថភាពស្តីពីកម្មវិធីអប់រំពហុភាសា | ១០០នាក់ | | x | x | x | x | -នា.អពស<br>-នា. អកប<br>-មគភ.សត<br>-មន្ទីរអយក | -នា.បស<br>-នា.អកត<br>-នា.បវ<br>-ដៃគូអភិវឌ្ឍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ៤០ ០០០ | -នា.អពស<br>-មន្ទីរអយក | របាយការណ៍<br>បំប៉នសមត្ថភាព<br>នា.អពស<br>មន្ទីរអយក |
| ៥.២.៣ ពង្រឹងការអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព | ៥.២.៣.១ បណ្តុះបណ្តាលនិងបំប៉នគ្រូបង្គោលថ្នាក់ក្រសួង ខេត្ត ស្រុក និងគ្រូបង្គោលភាសាជនជាតិដើមភាគតិច រួមទាំងគ្រូបង្គោលភាសាចារាយ ស្តីពីការអប់រំពហុភាសាសម្រាប់មត្តេយ្យសិក្សា និងបឋមសិក្សា | ចំនួនគ្រូបង្គោលថ្នាក់ក្រសួង ខេត្ត ស្រុក និងគ្រូ រួមទាំងគ្រូបង្គោលភាសាចារាយ | ១០០នាក់ រយៈពេល៥ឆ្នាំ | x | x | x | x | x | -នា.អពស<br>-មន្ទីរអយក<br>-ដៃគូអភិវឌ្ឍ<br>-នា.បវ | -នា.បវ<br>-នា.អកស<br>-ការិ.អយក<br>-នា.អកត<br>-នា.បស<br>-ដៃគូអភិវឌ្ឍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ១១៥ ០០០ | -នា.អពស<br>-មន្ទីរអយក | របាយការណ៍<br>នា.អពស<br>នា.បវ<br>មន្ទីរអយក |

## ៦.ផែនការសកម្មភាព

| យុទ្ធសាស្ត្រ / យុទ្ធសាស្ត្ររង | សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា(ឆ្នាំ) 1 | 2 | 3 | 4 | 5 | អង្គភាពទទួលខុសត្រូវចម្បង | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា(USD) | ការពិនិត្យតាមដាន និងវាយតម្លៃ | ប្រភពសម្រាប់ផ្ទៀងផ្ទាត់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ៥.២.៣.២ បណ្តុះបណ្តាលគ្រូបង្រៀនថ្នាក់អប់រំពហុភាសាថ្មី រួមទាំងគ្រូអប់រំពហុភាសានៃភាសាចារាយស្តីពីការអប់រំពហុភាសា | ចំនួនគ្រូថ្មី រួមទាំងគ្រូអប់រំពហុភាសានៃភាសាចារាយបានទទួលវគ្គបណ្តុះបណ្តាល | មតស (៣៣)<br>បស (៥៦)<br>អកប (២១) | x | x | x | x | x | -មន្ទីរអយក<br>-នា.អកប<br>-នា.អពស | -នា.បស<br>-នា.អកត<br>-នា.បវ<br>-ដៃគូអភិវឌ្ឍ<br>-មគភ.សត | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ៣២០ 000 | -នា.អពស<br>-នា.អកប<br>-មន្ទីរអយក<br>-មគភ.សត | របាយការណ៍បណ្តុះបណ្តាល មន្ទីរអយក នា.អពស មគភ.សត |
| | ៥.២.៣.៣ បំប៉នជាទៀងទាត់ដល់គ្រូអប់រំពហុភាសា រួមទាំងគ្រូអប់រំពហុភាសានៃភាសាចារាយស្តីពីវិធីសាស្ត្របង្រៀនអប់រំពហុភាសា និងអន្តរវប្បធម៌ | ភាគរយគ្រូអប់រំពហុភាសារួមទាំងគ្រូអប់រំពហុភាសានៃភាសាចារាយបានទទួលការបំប៉នជាទៀងទាត់ | ១០០%<br>រៀងរាល់ឆ្នាំ | x | x | x | x | x | -មន្ទីរអយក<br>-នា.អពស<br>-នា.អកប | -នា.អកត<br>-នា.បស<br>-នា.អកស<br>-នា.បវ<br>-ដៃគូអភិវឌ្ឍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ៣៣០ 000 | -នា.អពស<br>-នា.អកប<br>-មន្ទីរអយក | របាយការណ៍បំប៉ន នា.អពស មន្ទីរអយក |
| | ៥.២.៣.៤ បំប៉នគ្រូអប់រំពហុភាសា រួមទាំងគ្រូអប់រំពហុភាសានៃភាសាចារាយស្តីពីការផលិត និងប្រើប្រាស់សម្ភារបង្រៀន និងរៀនថ្នាក់អប់រំពហុភាសាសម្រាប់មត្តេយ្យសិក្សា និងបឋមសិក្សា | ភាគរយគ្រូអប់រំពហុភាសា និងគ្រូអប់រំពហុភាសានៃភាសាចារាយបានទទួលការបំប៉ន | ១០០%<br>រយៈពេល៥ឆ្នាំ | x | x | x | x | x | -នា.អពស<br>-មន្ទីរអយក | -នា.បវ<br>-នា.បស<br>-នា.អកស<br>-មគភ.សត<br>-ដៃគូអភិវឌ្ឍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ១២០ 000 | -នា.អពស<br>-មន្ទីរអយក | របាយការណ៍ នា.អពស មន្ទីរអយក |

## ៦.ផែនការសកម្មភាព

| យុទ្ធសាស្ត្រ / យុទ្ធសាស្ត្ររង | សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា(ឆ្នាំ) 1 | 2 | 3 | 4 | 5 | អង្គភាពទទួលខុសត្រូវចម្បង | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា(USD) | ការពិនិត្យតាមដាន និងវាយតម្លៃ | ប្រភពសម្រាប់ផ្ទៀងផ្ទាត់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ៥.២.៣.៥ បណ្តុះបណ្តាល និងបំប៉នគ្រូឧទ្ទេសអប់រំពហុភាសាសម្រាប់មជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តស្ទឹងត្រែង | ចំនួនគ្រូឧទ្ទេសអប់រំពហុភាសានៅមជ្ឈ.គរុកោសល្យភូមិភាគខេត្តស្ទឹងត្រែង | ១០នាក់ | | x | x | x | x | -នា.បវ<br>-នា.អពស<br>-នា.អកប<br>-ដៃគូអភិវឌ្ឍ<br>-មគភ.សត | -នា.អកស<br>-ដៃគូអភិវឌ្ឍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ៣៥ 000 | -នា.អពស<br>-នា.បវ<br>-មគភ.សត | របាយការណ៍<br>នា.បវ<br>នា.អពស<br>ដៃគូអភិវឌ្ឍ |
| | ៥.២.៣.៦ បណ្តុះបណ្តាលគរុសិស្សស្តីពីការអប់រំពហុភាសាមកពីខេត្តទាំង៥ នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តស្ទឹងត្រែង | ចំនួនគរុសិស្សមកពីខេត្តទាំង៥ជាជនជាតិដើមភាគតិចដែលបានទទួលការបណ្តុះបណ្តាលស្តីពីការអប់រំពហុភាសា | ៤០នាក់ | | | | x | x | -មគភ.សត<br>-នា.បវ<br>-មន្ទីរអយក<br>-ការិ.អយក | -នា.បស<br>-នា.អកត<br>-ដៃគូអភិវឌ្ឍ<br>-នា.អពស | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ៦០ 000 | -នា.បវ<br>-មគភ.សត | របាយការណ៍<br>មគភ.សត<br>នា.បវ<br>នា.អពស |
| | ៥.២.៣.៧ ពង្រឹងសមត្ថភាពមន្ត្រីអប់រំថ្នាក់ក្រសួង និងថ្នាក់ខេត្ត ស្រុក សាលារៀន និងតំណាងសហគមន៍ជនជាតិដើមភាគតិចតាមរយៈការចូលរួមទស្សនកិច្ចសិក្សា វគ្គបណ្តុះបណ្តាល សិក្ខាសាលា និងសន្និសីទក្នុងប្រទេស តំបន់ និងអន្តរជាតិ | ចំនួនអ្នកពាក់ព័ន្ធដែលបានចូលរួម | ៥៥នាក់ រយៈពេល៥ឆ្នាំ | x | x | x | x | x | -នា.អពស<br>-នា.អកប<br>-មន្ទីរអយក<br>-ការិ.អយក<br>-សាលារៀន<br>-ដៃគូអភិវឌ្ឍ | -នា.បស<br>-នា.អកត<br>-នា.បវ<br>-មគភ.សត<br>-សហគមន៍<br>-ដៃគូអភិវឌ្ឍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ១០០ 000 | -នា.អពស<br>-មន្ទីរអយក<br>-ការិ.អយក | របាយការណ៍<br>នា.អពស<br>នា.អកប<br>មន្ទីរអយក<br>ដៃគូអភិវឌ្ឍ |

## ៦.ផែនការសកម្មភាព

| យុទ្ធសាស្ត្រ / យុទ្ធសាស្ត្ររង | សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា(ឆ្នាំ) 1 | 2 | 3 | 4 | 5 | អង្គភាពទទួលខុសត្រូវចម្បង | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា(USD) | ការពិនិត្យតាមដាន និងវាយតម្លៃ | ប្រភពសម្រាប់ផ្ទៀងផ្ទាត់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **គោលដៅ២ ៖ ពង្រឹងការអប់រំពហុភាសាឱ្យមានគុណភាព ដោយផ្សារភ្ជាប់នឹងភាសាកំណើត វប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់របស់ជនជាតិដើមភាគតិច** | | | | | | | | | | | | | | |
| ៥.៣ យុទ្ធសាស្ត្រ៣៖ អភិវឌ្ឍកម្មវិធីសិក្សាអប់រំពហុភាសា និងសម្ភារសិក្សាដោយផ្សារភ្ជាប់នឹងវប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់របស់ជនជាតិដើមភាគតិច | | | | | | | | | | | | | | |
| ៥.៣.១ អភិវឌ្ឍកម្មវិធីសិក្សា និងសម្ភារសិក្សាអប់រំពហុភាសាសម្រាប់មត្តេយ្យសិក្សា និងបឋមសិក្សា រួមទាំងសម្រាប់ភាសាចារាយ | ៥.៣.១.១ ធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សាអប់រំពហុភាសា សម្រាប់មត្តេយ្យសិក្សា និងបឋមសិក្សា | ចំនួនកម្មវិធីដែលបានអភិវឌ្ឍ | ២<br>មតស (១)<br>បស (១) | x | x | x | x | x | -នា.អពស<br>-នា.អកស<br>-នា.អកត<br>-នា.បស<br>-ដៃគូអភិវឌ្ឍ | -នា.បវ<br>-ដៃគូអភិវឌ្ឍ<br>-សហគមន៍ | ថវិកាកម្មវិធី<br>ដៃគូអភិវឌ្ឍ | ១០០ ០០០ | -នា.អកស<br>-នា.អពស | របាយការណ៍<br>រៀបចំកម្មវិធីសិក្សា<br>នា.អពស |
| | ៥.៣.១.២ អភិវឌ្ឍសៀវភៅសិក្សា សៀវភៅមគ្គុទេសក៍គ្រូ ឯកសារបណ្តុះបណ្តាលគ្រូ និងសម្ភារបង្រៀន និងរៀនសម្រាប់កម្មវិធីអប់រំពហុភាសា រួមទាំងសម្រាប់ភាសាចារាយ | ចំនួនប្រភេទសៀវភៅឯកសារបានអភិវឌ្ឍ | ៤<br>-សៀវភៅសិក្សា<br>-មគ្គុទេសក៍គ្រូ<br>-ឯកសារ បណ្តុះបណ្តាលគ្រូ<br>-សម្ភារបង្រៀន និងរៀន | x | x | x | x | x | -នា.អពស<br>-នា.អកស<br>-មន្ទីរអយក<br>-ការិ.អយក<br>-ដៃគូអភិវឌ្ឍ | -នា.បស<br>-នា.អកត<br>-សាលារៀន<br>-ដៃគូអភិវឌ្ឍ<br>-សហគមន៍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ២០០ ០០០ | -នា.អពស<br>-មន្ទីរ.អយក<br>-ការិ.អយក | របាយការណ៍<br>នា.អពស<br>ដៃគូអភិវឌ្ឍ<br>នា.អកស |
| | ៥.៣.១.៣ បោះពុម្ព និងចែកចាយសៀវភៅសិក្សា សៀវភៅមគ្គុទ្ទេសក៍គ្រូ និងសម្ភារបង្រៀន និងរៀនដល់សាលារៀនដែលអនុវត្តកម្មវិធីអប់រំពហុភាសាសម្រាប់មត្តេយ្យសិក្សា និងបឋមសិក្សា រួមទាំងសម្រាប់ភាសាចារាយ | -ភាគរយគ្រូបានទទួលសៀវភៅមគ្គុទ្ទេសក៍ ឯកសារបណ្តុះបណ្តាល និងសិស្សបានទទួលសៀវភៅសិក្សា | -គ្រូ ១០០%<br>-សិស្ស ១០០%<br>ជារៀងរាល់ឆ្នាំ | x | x | x | x | x | -នា.អពស<br>-នា.អកត<br>-មន្ទីរអយក<br>-ការិ.អយក<br>-សាលារៀន<br>-ដៃគូអភិវឌ្ឍ | -ដៃគូអភិវឌ្ឍ<br>-សហគមន៍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ២០០ ០០០ | -នា.អពស<br>-មន្ទីរអយក | របាយការណ៍<br>បោះពុម្ព<br>ឯកសារ<br>នា.អពស<br>មន្ទីរអយក<br>ដៃគូអភិវឌ្ឍ |

## ៦.ផែនការសកម្មភាព

| យុទ្ធសាស្ត្រ / យុទ្ធសាស្ត្ររង | សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា(ឆ្នាំ) | | | | | អង្គភាពទទួលខុសត្រូវចម្បង | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា(USD) | ការពិនិត្យតាមដាន និងវាយតម្លៃ | ប្រភពសម្រាប់ផ្ទៀងផ្ទាត់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | 1 | 2 | 3 | 4 | 5 | | | | | | |
| ៥.៣.២ អភិវឌ្ឍកម្មវិធីសិក្សា និងសម្ភារសិក្សាអប់រំពហុភាសាសម្រាប់អប់រំក្រៅប្រព័ន្ធ | ៥.៣.២.១ ធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សាអប់រំពហុភាសាសម្រាប់អប់រំក្រៅប្រព័ន្ធ | -ចំនួនកម្មវិធីសិក្សាត្រូវបានកែសម្រួល | ១ | x | x | x | x | | -នា.អកប<br>-នា.អកស<br>-មន្ទីរអយក<br>-ការិ.អយក<br>-ដៃគូអភិវឌ្ឍ | -នា.បវ<br>-នា.អពស<br>-ដៃគូអភិវឌ្ឍ<br>-សហគមន៍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ១០០ ០០០ | -នា.អកស<br>-នា.អកប | របាយការណ៍<br>នា.អកប<br>ដៃគូអភិវឌ្ឍ |
| | ៥.៣.២.២ អភិវឌ្ឍសៀវភៅសិស្ស សៀវភៅគ្រូ និងសម្ភារបង្រៀន និងរៀនអប់រំពហុភាសាសម្រាប់អប់រំក្រៅប្រព័ន្ធ | -ចំនួនប្រភេទសៀវភៅសិស្ស សៀវភៅគ្រូ និងសម្ភារបង្រៀន និងរៀនត្រូវបានកែសម្រួល | ២ | x | x | x | x | | -នា.អកប<br>-នា.អកស<br>-ដៃគូអភិវឌ្ឍ | -នា.បស<br>-នា.អកត<br>-នា.អពស<br>-ដៃគូអភិវឌ្ឍ<br>-សហគមន៍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ១០០ ០០០ | -នា.អពស<br>-នា.អកស<br>-នា.អកប | របាយការណ៍<br>នា.អកប<br>នា.អកស |
| | ៥.៣.២.៣ បោះពុម្ព និងចែកចាយសៀវភៅសិស្ស សៀវភៅគ្រូ និងសម្ភារបង្រៀន និងរៀនដល់គ្រូ និងសិស្សអក្ខរកម្មអប់រំពហុភាសា | -ចំនួនគ្រូបានទទួលសៀវភៅគ្រូ<br>-ចំនួនសិស្សបានទទួលសៀវភៅសិស្ស គ្រប់គ្រាន់ | -គ្រូ២១នាក់<br>-សិស្ស ៩៦០ នាក់ | | x | x | x | x | -នា.អកប<br>-មន្ទីរអយក<br>-ការិ.អយក | -ដៃគូអភិវឌ្ឍ<br>នា.អកស<br>នា.បស | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ៣០ ០០០ | -នា.អកប<br>-នា.អពស | របាយការណ៍<br>បោះពុម្ព<br>នា.អកប<br>ដៃគូអភិវឌ្ឍ |
| ៥.៣.៣ អភិវឌ្ឍកម្មវិធីសិក្សា និងសម្ភារសិក្សាអប់រំពហុភាសាសម្រាប់ការបណ្តុះបណ្តាលគ្រូនៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តស្ទឹងត្រែង | ៥.៣.៣.១ រៀបចំកម្មវិធី និងឯកសារបណ្តុះបណ្តាលគ្រូស្តីពីការអប់រំពហុភាសានៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តស្ទឹងត្រែង | -ចំនួនកម្មវិធី និងឯកសារបណ្តុះបណ្តាលគ្រូអប់រំពហុភាសានៅមគភ.សត | ២ប្រភេទ<br>-កម្មវិធី<br>-ឯកសារបណ្តុះបណ្តាល | | x | x | x | x | -នា.បវ<br>-មគភ.សត<br>-នា.អពស<br>-នា.អកស<br>-ដៃគូអភិវឌ្ឍ | -នា.អកប<br>-មន្ទីរអយក<br>-ដៃគូអភិវឌ្ឍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ៨០ ០០០ | -នា.អពស<br>-នា.បវ | របាយការណ៍<br>នា.បវ<br>មគភ.សត |

## ៦.ផែនការសកម្មភាព

| យុទ្ធសាស្ត្រ / យុទ្ធសាស្ត្ររង | សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា(ឆ្នាំ) 1 | 2 | 3 | 4 | 5 | អង្គភាពទទួលខុសត្រូវចម្បង | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា(USD) | ការពិនិត្យតាមដាន និងវាយតម្លៃ | ប្រភពសម្រាប់ផ្ទៀងផ្ទាត់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ៥.៣.៣.២ បោះពុម្ពឯកសារបណ្តុះបណ្តាលកម្មវិធីអប់រំពហុភាសាសម្រាប់មជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តស្ទឹងត្រែង | ភាគរយគរុសិស្សជនជាតិដើមភាគតិចដែលបានទទួលឯកសារបណ្តុះបណ្តាលបន្ថែមកម្មវិធីអប់រំពហុភាសា | ១០០% | | | | x | x | -នា.បវ<br>-មគភ.សត<br>-ដៃគូអភិវឌ្ឍ | -នា.អពស<br>-នា.អកប<br>-នា.អកស<br>-មន្ទីរអេយក | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ១០ ០០០ | -នា.អពស<br>-នា.ប.វ | របាយការណ៍បោះពុម្ពនា.បវ មគភ.សត |
| ៥.៤ យុទ្ធសាស្ត្រទី៤៖ អភិវឌ្ឍ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធ សម្ភារសិក្សារូបវន្ត និងបរិស្ថានសាលារៀន | | | | | | | | | | | | | | |
| ៥.៤.១ រៀបចំ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធ សម្ភារសិក្សារូបវន្ត និងបរិស្ថានសាលារៀនដែលអនុវត្តកម្មវិធីអប់រំពហុភាសា | ៥.៤.១.១ សិក្សាស្ថានភាពជាក់ស្តែងនៅតាមសាលារៀនអប់រំពហុភាសានីមួយៗ (ហេដ្ឋារចនាសម្ព័ន្ធ សម្ភាររូបវន្ត និងបរិស្ថានសាលារៀន) | ចំនួនការសិក្សាស្ថានភាពជាក់ស្តែងនៅតាមសាលារៀនអប់រំពហុភាសា | ១ | | x | x | x | x | -ក.ស.អ<br>-នា.សំណង់<br>-មន្ទីរអេយក<br>-ការិ.អេយក<br>-សហគមន៍ | -នា.អពស<br>-នា.អកប<br>-នា.អកត<br>-នា.បស<br>-នា.គនប<br>- ដៃគូអភិវឌ្ឍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ៣០ ០០០ | -នា.សំណង់<br>-នា.អពស | របាយការណ៍មន្ទីរអេយក នា.សំណង់ |
| | ៥.៤.១.២ ផ្តល់អគារ បំពាក់សម្ភារសិក្សារូបវន្ត និងកញ្ចប់សម្ភារសិក្សា ដល់មត្តេយ្យសិក្សាសហគមន៍អប់រំពហុភាសាទទួលបានស្តង់ដាអប្បបរមា | ចំនួនថ្នាក់/មណ្ឌលមត្តេយ្យសិក្សាសហគមន៍អប់រំពហុភាសាទទួលបានកញ្ចប់ស្តង់ដាអប្បបរមា | ២៥ថ្នាក់/មណ្ឌល | x | x | x | x | x | -នា.អកត<br>-នា.សស<br>-មន្ទីរអេយក<br>-ការិ.អេយក<br>-ក្រុមប្រឹក្សាឃុំ/សង្កាត់<br>-ដៃគូអភិវឌ្ឍ<br>-សហគមន៍ | -សហគមន៍<br>-អាជ្ញាធរដែនដី<br>-នា.អពស | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ១៣៥ ០០០ | -មន្ទីរអេយក<br>-នា.អពស | របាយការណ៍មន្ទីរអេយក ការិ.អេយក នា.អពស នា.សំណង់ |

## ៦.ផែនការសកម្មភាព

| យុទ្ធសាស្ត្រ / យុទ្ធសាស្ត្ររង | សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា(ឆ្នាំ) | | | | | អង្គភាពទទួលខុសត្រូវចម្បង | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា(USD) | ការពិនិត្យតាមដាន និងវាយតម្លៃ | ប្រភពសម្រាប់ផ្ទៀងផ្ទាត់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | 1 | 2 | 3 | 4 | 5 | | | | | | |
| | ៥.៤.១.៣ សាងសង់ ឬកែលម្អអគារសិក្សា ឬថ្នាក់រៀនសម្រាប់សាលាអប់រំពហុភាសាកម្រិតបឋមសិក្សា | ចំនួនអគារសិក្សាឬថ្នាក់រៀនសម្រាប់សាលាអប់រំពហុភាសាដែលបានកែលម្អ | ៥កន្លែង រយៈពេល៥ឆ្នាំ | x | x | x | x | x | -មន្ទីរអយក<br>-ការិ.អយក<br>-នា.សំណង់<br>-ដៃគូអភិវឌ្ឍ<br>-សហគមន៍ | -នា.អពស<br>-ដៃគូអភិវឌ្ឍ<br>-សហគមន៍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ<br>-សប្បុរសជន | ៥០ 000 | -នា.សំណង់<br>-នា.អកត<br>-នា.អពស | របាយការណ៍<br>មន្ទីរអយក<br>នា.សំណង់ |
| | ៥.៤.១.៤ បង្កើតបណ្ណាល័យ ឬបណ្ណាល័យចល័តតាមសាលារៀនអប់រំពហុភាសាដែលមិនទាន់មាន (រួមទាំងសាងសង់ ឬជួសជុលបន្ទប់សម្រាប់បណ្ណាល័យ..) | ចំនួនបណ្ណាល័យឬបណ្ណាល័យចល័តតាមសាលារៀនអប់រំពហុភាសាដែលបានបង្កើតឡើង | ១០ រយៈពេល៥ឆ្នាំ | x | x | x | x | x | -នា.បស<br>-នា.អកត<br>-នា.អកប<br>-នា.សំណង់<br>-មន្ទីរអយក<br>-ការិ.អយក<br>-សាលារៀន | -នា.អពស<br>-សហគមន៍<br>-សាលារៀន<br>-ដៃគូអភិវឌ្ឍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ<br>-សប្បុរសជន | ៤០ 000 | -មន្ទីរអយក<br>-ការិ.អយក<br>-នា.អពស | របាយការណ៍<br>មន្ទីរអយក<br>ដៃគូអភិវឌ្ឍ<br>នា.សំណង់ |
| | ៥.៤.១.៥ សាងសង់មណ្ឌលធនធានសម្រាប់សិក្សាស្រាវជ្រាវ និងរក្សាឯកសារធនធាន វប្បធម៌ ប្រពៃណីរបស់សហគមន៍ជនជាតិដើមភាគតិច | ចំនួនមណ្ឌលធនធានសម្រាប់សិក្សាស្រាវជ្រាវភាសាជនជាតិដើមភាគតិចត្រូវបានសាងសង់ | ១ | | | | x | x | -នា.គនប<br>-នា.សំណង់<br>-មន្ទីរអយក<br>-ដៃគូអភិវឌ្ឍ<br>-នា.អពស<br>-នា.អកប | -សហគមន៍ជនជាតិដើមភាគតិច<br>-ដៃគូអភិវឌ្ឍ | -ដៃគូអភិវឌ្ឍ<br>-សប្បុរសជន | ១៥០ 000 | -នា.អពស<br>-នា.អកប<br>-នា.សំណង់<br>-នា.គនប | របាយការណ៍<br>មន្ទីរអយក<br>ដៃគូអភិវឌ្ឍ<br>នា.អពស<br>នា.គនប<br>នា.សំណង់ |

## ៦.ផែនការសកម្មភាព

| យុទ្ធសាស្ត្រ / យុទ្ធសាស្ត្ររង | សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា(ឆ្នាំ) | | | | | អង្គភាពទទួលខុសត្រូវចម្បង | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា(USD) | ការពិនិត្យតាមដាន និងវាយតម្លៃ | ប្រភពសម្រាប់ផ្ទៀងផ្ទាត់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | 1 | 2 | 3 | 4 | 5 | | | | | | |
| ៥.៥ យុទ្ធសាស្ត្រទី៥៖ ធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធព័ត៌មានគ្រប់គ្រងកម្មវិធីអប់រំពហុភាសា | | | | | | | | | | | | | | |
| ៥.៥.១ ចងក្រងប្រព័ន្ធព័ត៌មានគ្រប់គ្រងកម្មវិធីអប់រំពហុភាសាដោយបែងចែកតាមក្រុមជនជាតិដើមភាគតិច | ៥.៥.១.១ ប្រមូល និងគ្រប់គ្រងស្ថិតិកុមារជនជាតិដើមភាគតិចគ្រប់អាយុចូលរៀននៅកម្រិតមត្តេយ្យសិក្សា បឋមសិក្សាទាំងក្នុង និងក្រៅសាលារៀន និងអនក្ខរជនពេញវ័យ | ចំនួនខេត្តបានចងក្រងស្ថិតិ | ៥<br>រៀងរាល់ឆ្នាំ | x | x | x | x | x | -សាលារៀន<br>-ការិ.អយក<br>-មន្ទីរអយក<br>-នា.អពស<br>-នា.អកប<br>-អាជ្ញាធរ<br>-ក្រុមប្រឹក្សាឃុំ/ សង្កាត់ | -នា.បស<br>-នា.អកត<br>-សហគមន៍<br>-ដៃគូអភិវឌ្ឍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ២០ ០០០ | -នា.អពស<br>-ការិ.អយក<br>-មន្ទីរអយក<br>-នា.អពស<br>-នា.អកប | របាយការណ៍ស្ថិតិ សាលារៀន ការិ.អយក មន្ទីរអយក នា.អពស នពអ |
| | ៥.៥.១.២ ប្រមូល និងគ្រប់គ្រងលទ្ធផលសិក្សាប្រចាំឆមាស និងប្រចាំឆ្នាំរបស់សិស្សអប់រំពហុភាសា មត្តេយ្យសិក្សា បឋមសិក្សា និងអប់រំក្រៅប្រព័ន្ធ | ចំនួនខេត្តបានប្រមូល និងគ្រប់គ្រងលទ្ធផលសិក្សាប្រចាំឆមាស និងប្រចាំឆ្នាំរបស់សិស្សអប់រំពហុភាសា | ៥<br>រៀងរាល់ឆ្នាំ | x | x | x | x | x | -សាលារៀន<br>-ការិ.អយក<br>-មន្ទីរអយក<br>នា.អពស<br>នា.អកប | -នា.បស<br>-នា.អកត<br>-ដៃគូអភិវឌ្ឍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ២០ ០០០ | -នា.អពស<br>-នា.អកប | របាយការណ៍លទ្ធផលសិក្សា នា.អពស នា.អកប |
| | ៥.៥.១.៣ រៀបចំចងក្រង/បញ្ចូលស្ថិតិសិស្សជនជាតិដើមភាគតិចក្នុងប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ | ភាគរយស្ថិតិសិស្សជនជាតិដើមភាគតិចបានបញ្ចូលក្នុងប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ | ១០០% | | | | x | x | -នពអ<br>-នា.អពស<br>-មន្ទីរអយក<br>-ការិ.អយក<br>-សាលារៀន | -នា.អកត<br>-នា.បស<br>-ដៃគូអភិវឌ្ឍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ១៥ ០០០ | -នពអ<br>-នា.អពស | ស្ថិតិសម្រាប់ពិនិត្យតាមដាន នពអ នា.អពស |

## ៦.ផែនការសកម្មភាព

| យុទ្ធសាស្ត្រ / យុទ្ធសាស្ត្ររង | សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា(ឆ្នាំ) | | | | | អង្គភាពទទួលខុសត្រូវចម្បង | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា(USD) | ការពិនិត្យតាមដាន និងវាយតម្លៃ | ប្រភពសម្រាប់ផ្ទៀងផ្ទាត់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | 1 | 2 | 3 | 4 | 5 | | | | | | |
| **គោលដៅ៣ ៖ លើកកម្ពស់ការចូលរួមរបស់សហគមន៍ជនជាតិដើមភាគតិច និងកិច្ចសហប្រតិបត្តិការគ្រប់ភាគីពាក់ព័ន្ធ** | | | | | | | | | | | | | | |
| ៥.៦ យុទ្ធសាស្ត្រ៦៖ បង្កើនការចូលរួមរបស់ឪពុកម្តាយ សហគមន៍ជនជាតិដើមភាគតិច និងកិច្ចសហការជាមួយភាគីពាក់ព័ន្ធ ដើម្បីអនុវត្តកម្មវិធីអប់រំពហុភាសា | | | | | | | | | | | | | | |
| ៥.៦.១ លើកកម្ពស់ការចូលរួមរបស់ឪពុកម្តាយ និងសហគមន៍ជនជាតិដើមភាគតិច | ៥.៦.១.១ កសាងសមត្ថភាពគណៈកម្មការគ្រប់គ្រងសាលារៀនអប់រំពហុភាសាស្តីពីតួនាទី និងការទទួលខុសត្រូវ | ភាគរយគណៈកម្មការគ្រប់គ្រងសាលាបឋមសិក្សាអប់រំពហុភាសាត្រូវបានកសាងសមត្ថភាព | ៨០% | | x | x | x | x | -មន្ទីរអយក<br>-នា.អពស<br>-ការិ.អយក | -ដៃគូអភិវឌ្ឍ<br>-នា.បស<br>-នា.អកត<br>-សហគមន៍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ៣០ ០០០ | -នា.អពស<br>-នា.អកប<br>-មន្ទីរអយក | របាយការណ៍កសាងសមត្ថភាព នា.អពស នា.អកប មន្ទីរអយក |
| | ៥.៦.១.២ កសាងសមត្ថភាពជនបង្គោលអប់រំក្រៅប្រព័ន្ធថ្នាក់ឃុំ ដើម្បីគាំទ្រពិនិត្យតាមដានការបង្រៀន និងរៀនកម្មវិធីអប់រំពហុភាសាថ្នាក់អក្ខរកម្មក្រៅប្រព័ន្ធ | ចំនួនជនបង្គោលអប់រំក្រៅប្រព័ន្ធថ្នាក់ឃុំបានទទួលវគ្គបំប៉ន | ៣៦នាក់ រយៈពេល ៥ឆ្នាំ | x | x | x | x | x | -នា.អកប<br>-មន្ទីរអយក | -ការិ. អយក<br>-សាលារៀន<br>-នា.អពស<br>-ដៃគូអភិវឌ្ឍ<br>-សហគមន៍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ២០ ០០០ | -នា.អកប | របាយការណ៍កសាងសមត្ថភាព មន្ទីរអយក នា.អកប |
| | ៥.៦.១.៣ លើកកម្ពស់ការចូលរួមរបស់តំណាងសហគមន៍ជនជាតិដើមភាគតិចក្នុងការអភិវឌ្ឍកម្មវិធីសិក្សា សៀវភៅសិក្សា និងសម្ភារបង្រៀននិងរៀនដែលប្រើភាសាកំណើត | ចំនួនក្រុមតំណាងសហគមន៍ជនជាតិដើមភាគតិច | ៥ក្រុមជនជាតិដើមភាគតិចផ្សេងគ្នា | x | x | x | x | x | -មន្ទីរអយក<br>-ការិ.អយក<br>-ដៃគូអភិវឌ្ឍ | -នា.អកស<br>-នា.បវ<br>-នា.បស<br>-នា.អកត<br>-នា.អពស<br>-នា.អកប<br>-ដៃគូអភិវឌ្ឍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ១០ ០០០ | -មន្ទីរអយក<br>-នា.អពស<br>-នា.អកប | របាយការណ៍ មន្ទីរអយក នា.អពស ការិ.អយក |

## ៦.ផែនការសកម្មភាព

| យុទ្ធសាស្ត្រ / យុទ្ធសាស្ត្ររង | សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា(ឆ្នាំ) | | | | | អង្គភាពទទួលខុសត្រូវចម្បង | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា(USD) | ការពិនិត្យតាមដាន និងវាយតម្លៃ | ប្រភពសម្រាប់ផ្ទៀងផ្ទាត់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | 1 | 2 | 3 | 4 | 5 | | | | | | |
| | ៥.៦.១.៤ លើកកម្ពស់ការចូលរួមរបស់សហគមន៍ក្នុងការសាងសង់ និងថែរក្សាសាលារៀន អគារសិក្សា សម្ភារបរិក្ខារ និងអន្តេវាសិកដ្ឋានរបស់សិស្ស (ថវិកា ធនធាន ឬ កម្លាំងពលកម្ម) | ចំនួនសាលារៀនអប់រំពហុភាសាមានការចូលរួម | ១០សាលា | x | x | x | x | x | -ការិ.អយក<br>-មន្ទីរអយក<br>-សាលារៀន<br>-សហគមន៍ជនជាតិដើមភាគតិច | -នា.អពស<br>-នា.បស<br>-នា.អកត<br>-នា.អកប<br>-សហគមន៍ជនជាតិដើមភាគតិច<br>-ដៃគូអភិវឌ្ឍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ១០ ០០០ | -ការិ.អយក<br>-មន្ទីរអយក<br>-សាលារៀន<br>-សហគមន៍ជនជាតិដើមភាគតិច<br>-នា.អពស | របាយការណ៍ចូលរួមសាលារៀន ការិ. អយក មន្ទីរអយក |
| | ៥.៦.១.៥ ពង្រឹងកិច្ចសហប្រតិបត្តិការ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍនានា ដើម្បីលើកកម្ពស់គុណភាពកម្មវិធីអប់រំពហុភាសា | ចំនួនស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍដែលបានចូលរួមការប្រជុំបូកសរុបការវាយតម្លៃការអនុវត្តនានា... | ៥ស្ថាប័នពាក់ព័ន្ធ នាយកដ្ឋាន ឬដៃគូអភិវឌ្ឍពាក់ព័ន្ធ ការិ.អយក មន្ទីរ.អយក | x | x | x | x | x | -មន្ទីរអយក<br>-ការិ.អយក<br>-សាលារៀន<br>-នា.អពស<br>-ដៃគូអភិវឌ្ឍ | -នា.បស<br>-នា.អកស<br>-នា.អកត<br>-នា.បវ<br>-នា.អពស | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ១០ ០០០ | -នា.អពស<br>-មន្ទីរអយក<br>-ការិ.អយក | របាយការណ៍សហការ មន្ទីរអយក ការិ.អយក នា.អពស |
| ៥.៦.២ បង្កើន និងពង្រឹងកិច្ចសហការជាមួយអ្នកពាក់ព័ន្ធ ដើម្បីអនុវត្តកម្មវិធីអប់រំពហុភាសា | ៥.៦.២.១ សហការជាមួយរាជបណ្ឌិតសភាកម្ពុជា ដើម្បីពិនិត្យឡើងវិញ និងកែលម្អលើភាសាជនជាតិដើមភាគតិច | ចំនួនភាសាត្រូវបានដាក់ពិភាក្សា | ១ភាសា (ចារាយ) | x | x | x | x | x | -នា.អពស<br>-នា.អកប<br>-ដៃគូអភិវឌ្ឍ<br>-នា.អកស | -នា.គនប<br>-នា.បវ<br>-នា.បស<br>-នា.អកត<br>-ដៃគូអភិវឌ្ឍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ៣០ ០០០ | -នា.អពស<br>-នា.អកប | របាយការណ៍សហការ នា.អពស នា.អកប |

## ៦.ផែនការសកម្មភាព

| យុទ្ធសាស្ត្រ / យុទ្ធសាស្ត្ររង | សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា(ឆ្នាំ) | | | | | អង្គភាពទទួលខុសត្រូវចម្បង | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា(USD) | ការពិនិត្យតាមដាន និងវាយតម្លៃ | ប្រភពសម្រាប់ផ្ទៀងផ្ទាត់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | 1 | 2 | 3 | 4 | 5 | | | | | | |
| | ៥.៦.២.២ សហការជាមួយសាកលវិទ្យាល័យ និងវិទ្យាស្ថាននានា ដើម្បីសិក្សាស្រាវជ្រាវពីភាសាកំណើតរបស់ជនជាតិដើមភាគតិចនីមួយៗ និង/ ឬការសិក្សានានាពាក់ព័ន្ធនឹងការអប់រំពហុភាសា | ចំនួនឯកសារដែលបានស្រាវជ្រាវ និងចងក្រង | ៣<br>រយៈពេល៥ឆ្នាំ | x | x | x | x | x | -នា.អពស<br>-នា.អកប<br>-នា.គនប<br>-ដៃគូអភិវឌ្ឍ<br>-សកលវិទ្យាល័យនានា<br>-ក.ស.អ | -នា.បវ<br>-មន្ទីរអយក<br>-ការិ.អយក<br>-ដៃគូអភិវឌ្ឍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ៥០ ០០០ | -នា.អពស<br>-នា.អកប | របាយការណ៍សហការ នា.អពស នា.អកប ដៃគូអភិវឌ្ឍ សកលវិទ្យាល័យនានា |
| | ៥.៦.២.៣ លើកកម្ពស់ការចូលរួមរបស់តំណាងសហគមន៍ជនជាតិដើមភាគតិចក្នុងការអភិវឌ្ឍ និងអភិរក្សភាសាកំណើតតាមរយៈវេទិកានានា និងយន្តការថ្នាក់ជាតិ តំបន់ និងអន្តរជាតិ | ចំនួនតំណាងសហគមន៍ចូលរួមក្នុងកម្មវិធីនានា | ៧ក្រុមជនជាតិដើមភាគតិច | | x | x | x | x | -សាលារៀន<br>-មន្ទីរអយក<br>-ការិ.អយក<br>-សហគមន៍ជនជាតិដើមភាគតិច | -សហគមន៍<br>-ដៃគូអភិវឌ្ឍ<br>-នា.អពស<br>-នា.អកប | -ដៃគូអភិវឌ្ឍ | ១៥ ០០០ | -នា.អពស<br>-មន្ទីរអយក<br>-ការិ.អយក | របាយការណ៍សហការ មន្ទីរអយក ការិ.អយក |
| ៥.៧ យុទ្ធសាស្ត្រទី៧៖ ពង្រឹងយន្តការពិនិត្យតាមដាន និងវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស និងគុណភាពបង្រៀន និងរៀន | | | | | | | | | | | | | | |
| ៥.៧.១ វាយតម្លៃការសិក្សារបស់សិស្ស | ៥.៧.១.១ រៀបចំកម្រងសំណួរតេស្តវាយតម្លៃលទ្ធផលសិក្សាសម្រាប់ដើមឆ្នាំ ឆមាស ដំណាច់ឆ្នាំសិក្សា | ចំនួនកម្រងសំណួរតេស្តវាយតម្លៃការសិក្សារបស់សិស្សដែលបានបង្កើត | ៣ ឧបករណ៍<br>-មតស<br>-បស (ពីថ្នាក់ទី ១ ដល់ទី៣)<br>-អប់រំក្រៅប្រព័ន្ធ | x | x | x | x | x | -សាលារៀន<br>-មន្ទីរអយក<br>-ការិ.អយក<br>-សហគមន៍ | -នា.អកស<br>-នា.បស<br>-នា.អកត<br>-នា.អពស<br>-នា.ធគអ<br>-ដៃគូអភិវឌ្ឍ<br>-នា.អកប | ថវិកាកម្មវិធី<br>ដៃគូអភិវឌ្ឍ | ៥០ ០០០ | -មន្ទីរអយក<br>-ការិ.អយក<br>-នា.អពស<br>-នា.ធគអ<br>-នា.អកស<br>-នា.បស<br>-នា.អកប | របាយការណ៍សាលារៀន មន្ទីរអយក ការិ.អយក |

## ៦.ផែនការសកម្មភាព

| យុទ្ធសាស្ត្រ / យុទ្ធសាស្ត្ររង | សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា(ឆ្នាំ) 1 | 2 | 3 | 4 | 5 | អង្គភាពទទួលខុសត្រូវចម្បង | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា(USD) | ការពិនិត្យតាមដាន និងវាយតម្លៃ | ប្រភពសម្រាប់ផ្ទៀងផ្ទាត់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ៥.៧.១.២ រៀបចំកម្រងសំណួរតេស្តវាយតម្លៃស្តង់ដាការសិក្សារបស់សិស្សថ្នាក់អប់រំពហុភាសា(ថ្នាក់ទី៣) | ចំនួនតេស្តស្តង់ដា | ១ | | | | | x | -នា.ធគអ<br>-នា.អពស<br>-នា.បស<br>-មន្ទីរអយក<br>-ការិ.អយក<br>-សាលារៀន | -នា.អកស<br>-នា.បវ<br>-សាលារៀន<br>-ដៃគូអភិវឌ្ឍ | ថវិកាកម្មវិធី<br>ដៃគូអភិវឌ្ឍ | ៣០ ០០០ | -នា.អពស<br>-នា.ធគអ | របាយការណ៍<br>នា.ធគអ<br>នា.អពស |
| | ៥.៧.១.៣ ធ្វើការសិក្សារយៈពេលវែងដើម្បីតាមដានការរីកចំរើននៃលទ្ធផលសិក្សារបស់សិស្សអប់រំពហុភាសា | ចំនួនការសិក្សាស្រាវជ្រាវរយៈពេលវែង | ២<br>រយៈពេល៥ឆ្នាំ | | x | x | x | x | -ក.ស.អ<br>-នា.គនប<br>-សកលវិទ្យាល័យនានា<br>-នា.អពស<br>-ដៃគូអភិវឌ្ឍ | -មន្ទីរអយក<br>-ការិ.អយក<br>-ដៃគូអភិវឌ្ឍ<br>-សហគមន៍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ៨០ ០០០ | -នា.អពស<br>-នា.គនប | របាយការណ៍<br>-ក.ស.អ<br>-សកលវិទ្យាល័យនានា |
| ៥.៧.២ ពិនិត្យតាមដាននិងវាយតម្លៃសកម្មភាពបង្រៀននិងរៀនសម្រាប់មត្តេយ្យសិក្សានិងថ្នាក់អក្ខរកម្មអប់រំពហុភាសា | ៥.៧.២.១ អភិវឌ្ឍឧបករណ៍ពិនិត្យតាមដានការរៀននិងបង្រៀនថ្នាក់អប់រំពហុភាសា | ចំនួនឧបករណ៍តាមដានការរៀន និងបង្រៀន ដែលបានកែសម្រួល ( មតស និង អកប) | ២ | | | x | x | x | -នា.អពស<br>-នា.អបក<br>-នា.ធគអ<br>- នា.បវ<br>-នា.អកត<br>-មន្ទីរអយក | -នា.អកស<br>-នា.បស<br>-ការិ.អយក<br>-សាលារៀន<br>-ដៃគូអភិវឌ្ឍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ៣០ ០០០ | -នា.អពស | ពិនិត្យឧបករណ៍ពិនិត្យតាមដានការរៀន និងបង្រៀន |
| | ៥.៧.២.២ ពិនិត្យតាមដានការរៀន និងបង្រៀនថ្នាក់អប់រំពហុភាសាជាប្រចាំ | ចំនួនការចុះពិនិត្យតាមដានការរៀននិងបង្រៀន | ២ដងក្នុង១ឆ្នាំ | x | x | x | x | x | -នា.អពស<br>-នា.អកប<br>-មន្ទីរអយក<br>-ការិ.អយក<br>-សាលារៀន | -នា.បស<br>-នា.អកត<br>-ដៃគូអភិវឌ្ឍ<br>-សហគមន៍ | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ១២០ ០០០ | -នា.អពស<br>-មន្ទីរអយក<br>-ការិ.អយក | របាយការណ៍<br>មន្ទីរអយក<br>នា.អពស<br>នា.អកប |

## ៦.ផែនការសកម្មភាព

| យុទ្ធសាស្ត្រ / យុទ្ធសាស្ត្ររង | សកម្មភាព | សូចនាករ | ចំណុចដៅ | ក្របខណ្ឌពេលវេលា(ឆ្នាំ) | | | | | អង្គភាពទទួលខុសត្រូវចម្បង | ស្ថាប័នផ្តល់ការគាំទ្រ | ប្រភពជំនួយ | ថវិកា(USD) | ការពិនិត្យតាមដាន និងវាយតម្លៃ | ប្រភពសម្រាប់ផ្ទៀងផ្ទាត់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | 1 | 2 | 3 | 4 | 5 | | | | | | |
| | ៥.៧.២.៣ ប្រជុំបូកសរុបការងារអប់រំពហុភាសា | ចំនួនការប្រជុំបូកសរុប | -១ឆ្នាំម្តងក្នុងមួយខេត្ត<br>-ប្រជុំរួមធំម្តងក្នុង១ឆ្នាំ | x | x | x | x | x | -មន្ទីរអយក<br>-ការិ.អយក<br>-នា.អពស<br>-នា.អកប | -នា.ផក<br>-នា.បស<br>-នា.អកត<br>-នា.សស | -ថវិកាកម្មវិធី<br>-ដៃគូអភិវឌ្ឍ | ១០០ ០០០ | -នា.អពស<br>-នា.អកប<br>-មន្ទីរអយក<br>-ការិ.អយក | របាយការណ៍<br>មន្ទីរអយក<br>នា.អពស<br>នា.អកប |

## ៧.ការពិនិត្យតាមដានការអនុវត្តផែនការសកម្មភាពស្តីពីការអប់រំពហុភាសា២០១៩-២០២៣

ដើម្បីឱ្យផែនការសកម្មភាពស្តីពីការអប់រំពហុភាសា ២០១៩-២០២៣ សម្រេចបានជោគជ័យ និងមានប្រសិទ្ធភាពត្រូវ៖

- បង្កើតក្រុមការងារអប់រំពហុភាសាសម្រាប់ពិនិត្យតាមដានការអនុវត្តផែនការសកម្មភាព ស្តីពីការអប់រំពហុភាសា ២០១៩-២០២៣ សម្រាប់ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្ត និងការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក
- បន្សុីផែនការសកម្មភាពស្តីពីការអប់រំពហុភាសា ២០១៩-២០២៣ ទៅនឹងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣
- ដាក់បញ្ចូលសកម្មភាពនៃផែនការសកម្មភាពស្តីពីការអប់រំពហុភាសា ២០១៩-២០២៣ ទៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ផែនការអភិវឌ្ឍសាលារៀន និងផែនការវិនិយោគឃុំ/សង្កាត់
- ពិនិត្យតាមដានជាទៀងទាត់លើការអនុវត្តផែនការសកម្មភាពស្តីពីការអប់រំពហុភាសា ២០១៩-២០២៣ប្រចាំឆ្នាំ
- ប្រជុំបូកសរុបការអនុវត្តផែនការសកម្មភាពស្តីពីការអប់រំពហុភាសា ២០១៩-២០២៣ ពាក់កណ្តាលអណត្តិឆ្នាំ២០២១
- ប្រជុំបូកសរុបបញ្ចប់ និងវាយតម្លៃការអនុវត្តផែនការសកម្មភាព ស្តីពីការអប់រំពហុភាសា២០១៩-២០២៣ ដើម្បីពិនិត្យនូវភាពពាក់ព័ន្ធ ប្រសិទ្ធភាព ប្រសិទ្ធផល ផលជះ និងនិរន្តរភាព នៅឆ្នាំ២០២៣
- បន្តរៀបចំផែនការសកម្មភាពស្តីពីការអប់រំពហុភាសា ២០២៤-២០២៨

## ៨. គម្រោងចំណាយតាមយុទ្ធសាស្ត្រ

ចំណោលចំណាយសម្រាប់អនុវត្តផែនការសកម្មភាពស្តីពីការអប់រំពហុភាសា ២០១៩-២០២៣ មានទឹកប្រាក់ចំនួនUSD ៩ ៣៣៨ ២៣០,០០ ដើម្បីអនុវត្តរយៈពេល៥ឆ្នាំ លើយុទ្ធសាស្ត្រទាំង៧ ការពិនិត្យតាមដាន និងការវាយតម្លៃផែនការសកម្មភាពស្តីពីការអប់រំពហុភាសា ២០១៩-២០២៣ ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភប្រចាំខែរបស់គ្រូ ការគាំទ្រមធ្យោបាយ និងសម្ភារសម្រាប់អនុវត្តការងារអប់រំពហុភាសា៖

- យុទ្ធសាស្ត្រ១ ៖ USD ២ ០៦០ ១៣០,០០
- យុទ្ធសាស្ត្រ២ ៖ USD ១ ២១៧ ០០០,០០
- យុទ្ធសាស្ត្រ៣ ៖ USD ៨២០ ០០០,០០
- យុទ្ធសាស្ត្រ៤ ៖ USD ៤០៥ ០០០,០០
- យុទ្ធសាស្ត្រ៥ ៖ USD ៥៥ ០០០,០០
- យុទ្ធសាស្ត្រ៦ ៖ USD ១៧៥ ០០០,០០
- យុទ្ធសាស្ត្រ៧ ៖ USD ៤១០ ០០០,០០
- ការពិនិត្យតាមដាន និងវាយតម្លៃផែនការសកម្មភាពស្តីពីការអប់រំពហុភាសា ២០១៩-២០២៣៖ USD ១០០ ០០០,០០
- បៀវត្ស និងប្រាក់ឧបត្ថម្ភប្រចាំខែរបស់គ្រូបង្រៀនអប់រំពហុភាសាទាំងមត្តេយ្យសិក្សា បឋមសិក្សា និងក្រៅប្រព័ន្ធ៖ USD ៣ ៩៦០ ១០០,០០
- ផ្តល់មធ្យោបាយ និងសម្ភារសម្រាប់គាំទ្រការអប់រំពហុភាសា រថយន្ត ០៣គ្រឿង ម៉ូតូ១០គ្រឿង ៖ USD ១៣៦ ០០០,០០

****សម្រាប់ប្រាក់បៀវត្សគ្រូបង្រៀនថ្នាក់អប់រំពហុភាសានឹងប្រើប្រាស់ថវិការដ្ឋ សរុបប្រហែល USD ៣ ៩៦០ ១០០,០០*

## ៩.សេចក្ដីសន្និដ្ឋាន

ផែនការសកម្មភាព ស្ដីពីការអប់រំពហុភាសា ២០១៩-២០២៣ សម្រាប់គាំទ្រដល់ការអប់រំពហុភាសាតំបន់ខ្ពង់រាបនៃភាគឦសាននៅខេត្តរតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ក្រចេះ និងខេត្តព្រះវិហារ ជួយដល់កុមារជនជាតិដើមភាគតិចទទួលបានការអប់រំប្រកបដោយសមធម៌ និងបរិយាបន្ន។ ផែនការនេះជាត្រីវិស័យដ៏សំខាន់សម្រាប់ជួយជំរុញក្នុងការសម្រេចគោលដៅរបស់ក្រសួងអប់រំ យុវជន និងកីឡា និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ ជាពិសេសជួយដល់ការអភិវឌ្ឍធនធានមនុស្សដោយផ្សារភ្ជាប់វប្បធម៌ និងតម្រូវការជាក់ស្ដែងរបស់សហគមន៍ជនជាតិដើមភាគតិច។

ការអនុវត្តផែនការនេះត្រូវពឹងផ្អែកលើធនធានហិរញ្ញវត្ថុ ធនធានមនុស្ស និងសម្ភារគាំទ្រដែល ក្រសួងអប់រំ យុវជន និងកីឡា បានដាក់បញ្ចូលក្នុងផែនការសកម្មភាព ស្ដីពីការអប់រំពហុភាសា ២០១៩-២០២៣ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០១៩-២០២៣ និងការចូលរួមគាំទ្រពីគ្រប់អ្នកពាក់ព័ន្ធ ដៃគូអភិវឌ្ឍ និងសហគមន៍។

ក្រសួងអប់រំ យុវជន និងកីឡា សង្ឃឹម និងជឿជាក់ថាស្ថាប័ន នាយកដ្ឋាន ដៃគូអភិវឌ្ឍ និងអ្នកពាក់ព័ន្ធទាំងអស់ចូលរួមគាំទ្រ និងជំរុញការអនុវត្តផែនការសកម្មភាពស្ដីពីការអប់រំពហុភាសា ២០១៩-២០២៣ ដោយរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ ដាក់បញ្ចូលនូវសកម្មភាពជាអាទិភាព ដើម្បីសម្រេចគោលដៅ និងសកម្មភាពនៃផែនការនេះប្រកបដោយជោគជ័យ និងប្រសិទ្ធភាពខ្ពស់។

## ១០.ឧបសម្ព័ន្ធ
### ១០.១ បញ្ជីពាក្យកាត់

| | | |
|---|---|---|
| ការិ.អយក | : | ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក |
| ក.ស.អ | : | ក្រុមប្រឹក្សាស្រាវជ្រាវអប់រំ |
| នពអ | : | នាយកដ្ឋានព័ត៌មានគ្រប់គ្រងអប់រំ |
| នា.គនប | : | នាយកដ្ឋានគោលនយោបាយ |
| នា. ធគអ | : | នាយកដ្ឋានធានាគុណភាពអប់រំ |
| នា. បល | : | នាយកដ្ឋានបុគ្គលិក |
| នា. បវ | : | នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ |
| នា. បស | : | នាយកដ្ឋានបឋមសិក្សា |
| នា. ផក | : | នាយកដ្ឋានផែនការ |
| នា. មចទ | : | នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ |
| នា. សំណង់ | : | នាយកដ្ឋានសំណង់ |
| នា. សស | : | នាយកដ្ឋានសុខភាពសិក្សា |
| នា. អកត | : | នាយកដ្ឋានអប់រំកុមារតូច |
| នា. អកប | : | នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| នា. អកស | : | នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា |
| នា. អពស | : | នាយកដ្ឋានអប់រំពិសេស |
| នា.បវព | : | នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន |
| បស | : | បឋមសិក្សា |
| មតស | : | មត្តេយ្យសិក្សា |
| មគភ.សត | : | មជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តស្ទឹងត្រែង |
| មន្ទីរអយក | : | មន្ទីរអប់រំ យុវជន និងកីឡាខេត្ត |
| សគវខ.ពហ | : | សាលាគរុកោសល្យ និងវិក្រឹតការខេត្តព្រះវិហារ |
| សគវខ.ក្រច | : | សាលាគរុកោសល្យ និងវិក្រឹតការខេត្តក្រចេះ |
| សគមម | : | សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈឹម |
| អកប | : | អប់រំក្រៅប្រព័ន្ធ |

## ១០.២ សទ្ទានុក្រម

ការអប់រំពហុភាសាជាការបង្រៀនអក្ខរកម្មដំបូង (ការអាន សរសេរ និងគិតលេខ) ជាភាសាកំណើត (ភាសាទី១) ដោយមានការបង្រៀនជាភាសាទី២បន្ថែម ដោយប្រើវិធីសាស្ត្រសមស្របក្នុងការផ្ទេរចំណេះដឹងអក្ខរកម្មពីភាសាកំណើតទៅភាសាទី២ និងផ្លាស់ប្តូរជាលំដាប់ពីភាសាកំណើតដែលជាភាសាប្រើក្នុងការបង្រៀនទៅជាការប្រើប្រាស់ភាសាកំណើត (L1) និងភាសាទី២ (L2) តាមរយៈវិធីសាស្ត្រអប់រំពហុភាសា។ វិធីសាស្ត្រនេះជាមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់អក្ខរកម្ម និងជំនាញនៃការយល់ដឹងនៅក្នុងភាសាកំណើតដែលអាចផ្ទេរទៅភាសាទី២បាន។

កម្មវិធីអប់រំពហុភាសាផ្តោតលើការជួយដល់សិស្សានុសិស្ស ក្នុងការកសាងមូលដ្ឋានគ្រឹះដ៏រឹងមាំជាភាសាកំណើត (ភាសាទី១) ហើយប្រើជាស្ពានក្នុងការរៀនភាសាជាតិ (ភាសាទី២) ភាសាកំណើតត្រូវបានកំណត់ជាភាសាដែលបុគ្គលម្នាក់ៗចេះមុនគេ ហើយកំណត់អត្តសញ្ញាណជាមួយការដឹងប្រសើរបំផុត ប្រើច្រើនបំផុត ចេះនិយាយ និងយល់គ្រប់គ្រាន់ដើម្បីរៀននូវខ្លឹមសារដែលសមស្របតាមកម្រិតអាយុ។

ជនជាតិដើមភាគតិច គឺជាជនជាតិដែលរស់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ហើយជនទាំងនោះបង្ហាញនូវឯកភាពជាតិពន្ធុ សង្គម វប្បធម៌ និងសេដ្ឋកិច្ច ប្រតិបត្តិរបៀបរស់នៅតាមបែបប្រពៃណី និងការដាំដុះលើដីដែលខ្លួនកាន់កាប់ទៅតាមក្បួនខ្នាត ទំនៀមទម្លាប់នៃការប្រើប្រាស់ដីជាសមូហភាព។ *(គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច ទំព័រទី១ សម័យប្រជុំពេញអង្គនាថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៩)*

ភាសាជាតិ សំដៅដល់ភាសាដែលប្រើជាផ្លូវការក្នុងព្រះរាជាណាចក្រកម្ពុជា។

ភាសាទី១ គឺជាភាសាកំណើតរបស់ជនជាតិ ដែលបានប្រើប្រាស់សម្រាប់ប្រាស្រ័យទាក់ទងជាប្រចាំនៅក្នុងគ្រួសារដែលយល់ន័យច្បាស់លាស់។

ភាសាទី២ គឺជាភាសាដែលមិនមែនជាភាសាកំណើត និងប្រើប្រាស់សម្រាប់ប្រាស្រ័យទាក់ទងពីជនជាតិមួយទៅជនជាតិមួយទៀត សម្រាប់កម្មវិធីអប់រំពហុភាសាភាសាទី២គឺភាសាខ្មែរ។

មត្តេយ្យសិក្សាសហគមន៍ សំដៅដល់មណ្ឌល ឬថ្នាក់មត្តេយ្យសិក្សានៅតាមឃុំ សង្កាត់ដែលបង្កើតឡើងដោយរដ្ឋបាលឃុំ សង្កាត់ដោយប្រើប្រាស់នូវមូលនិធិរបស់ឃុំ សង្កាត់ ឬបានទទួលការគាំទ្រពីដៃគូអភិវឌ្ឍ ឬសប្បុរសជននានា។

## ១០.៣ អត្ថប្រយោជន៍ នៃការអប់រំពហុភាសា

នៅក្នុងកម្មវិធីអប់រំពហុភាសាដែលមានប្រសិទ្ធភាព សិស្សនឹងមានសមត្ថភាពក្នុងការទំនាក់ទំនងដោយប្រើភាសាទី២បានយ៉ាងល្អដូចជាភាសាកំណើតដែរ ហើយអាចអាន សរសេរ និងរៀនជាភាសាទាំងពីរទៀតផង។ ចាប់ផ្តើមពីការរៀនភាសាកំណើត ជាភាសាដែលពួកគាត់ចេះច្បាស់បំផុតនឹងជួយកសាងគ្រឹះដ៏រឹងមាំដែលអាចជួយឱ្យពួកគាត់ផ្ទេរទៅភាសាទី២យ៉ាងមានប្រសិទ្ធភាព។

ភស្តុតាងបានបង្ហាញថាកុមាររៀនសូត្របានល្អបំផុត នៅពេលពួកគាត់ប្រើអ្វីដែលពួកគាត់បានដឹងរួចហើយ (ចំណេះដឹង បទពិសោធ និងភាសារបស់ពួកគាត់) ដើម្បីរៀនពីអ្វីដែលថ្មី(ការពិត គំនិត និងភាសាថ្មីៗ)។ កុមារដែលមានគ្រឹះដ៏រឹងមាំនៅក្នុងភាសាកំណើតរបស់ពួកគាត់នឹងអភិវឌ្ឍសមត្ថភាពអក្ខរកម្មកាន់តែខ្លាំងនៅក្នុងភាសាទី២។

**កម្មវិធីអប់រំពហុភាសាត្រូវបានអនុវត្តដោយជោគជ័យនៅជុំវិញពិភពលោកនៅក្នុងប្រទេសជាច្រើន**

ភស្តុតាងពីការសិក្សាស្រាវជ្រាវបានគាំទ្រដល់សេចក្តីសន្និដ្ឋានដូចខាងក្រោម៖

- ភាសាកំណើតរបស់កុមារ(L1) មានសារៈសំខាន់ណាស់ក្នុងការអភិវឌ្ឍជំនាញមុនអក្ខរកម្ម ការបង្កើតអត្តសញ្ញាណ ការផ្សារភ្ជាប់ទៅនឹងចំណេះដឹង និងបទពិសោធដែលមានស្រាប់
- សិស្សអប់រំពហុភាសាអភិវឌ្ឍជំនាញអក្ខរកម្មបានយ៉ាងងាយស្រួលក្នុងភាសា ដែលពួកគាត់ស្គាល់ច្បាស់នឹងនាំឱ្យមានអត្រាអក្ខរកម្មខ្ពស់
- សិស្សអប់រំពហុភាសាអភិវឌ្ឍជំនាញការយល់ដឹង និងមានការយល់ដឹងពីខ្លឹមសារមេរៀនកាន់តែប្រសើរឡើងនៅពេលបង្រៀនពួកគាត់ ដោយប្រើភាសាដែលពួកគាត់ចេះស្ទាត់ នឹងបានផ្តល់ឱកាសស្មើគ្នាដើម្បីរៀនគ្រប់មុខវិជ្ជាដែលបង្រៀននៅតាមសាលារៀន
- ការប្រើប្រាស់ភាសាកំណើតជួយពង្រឹងភាពក្លាហាន ភាពជឿជាក់លើខ្លួនឯង និងអត្តសញ្ញាណរបស់ពួកគាត់ដែលនាំឱ្យមានការកើនឡើងនូវការលើកទឹកចិត្ត ការចូលរួម និងការបង្កើតថ្មី
- ការអប់រំដែលផ្តោតលើភាសាកំណើតនាំឱ្យមានភាពប្រសើរឡើងក្នុងការចូលរៀន មានការថយចុះនូវការរៀនត្រួតថ្នាក់ និងការបោះបង់ចោលការសិក្សា ក៏ដូចជាលើកកម្ពស់សមភាពយេនឌ័រ
- ភាសា និងវប្បធម៌របស់ជនជាតិដើមភាគតិចត្រូវបានពង្រឹង គ្រូជនជាតិដើមភាគតិចដែលត្រូវបានបណ្តុះបណ្តាលទទួលបានការងារជាគ្រូបង្រៀននៅបឋមសិក្សា និងជាគ្រូសហគមន៍មត្តេយ្យសិក្សា
- ឪពុកម្តាយ និងសហគមន៍ជនជាតិដើមភាគតិច ចូលរួមអភិវឌ្ឍកម្មវិធីសិក្សាអប់រំពហុភាសារបស់កូនៗ ការរៀនសូត្ររបស់សិស្សអាចត្រូវបានវាយតម្លៃយ៉ាងត្រឹមត្រូវ នៅពេលដែលពួកគាត់អាចបញ្ជាក់ពីខ្លួនឯងបាន នេះក៏អាចជួយឱ្យគ្រូបង្រៀនធ្វើការវិភាគលើអ្វីដែលសិស្សបានរៀនរួចហើយ អ្វីដែលត្រូវបង្រៀនពួកគាត់ ហើយសិស្សណាដែលត្រូវការជំនួយបន្ថែម
- សិស្សនឹងចេះអក្ខរកម្មពីរភាសា និយាយ អាន និងសរសេរបានច្រើនជាងមួយភាសា
- កម្មវិធីសិក្សាអប់រំពហុភាសាផ្អែកលើវប្បធម៌របស់សហគមន៍ជនជាតិដើមភាគតិច ដែលជាអ្នកជំនាញក្នុងវប្បធម៌របស់ពួកគាត់ ដោយប្រើចំណេះដឹងមូលដ្ឋាន និងការអនុវត្តដែលធ្វើឱ្យអ្នកសិក្សាអភិវឌ្ឍគោលគំនិតជាមូលដ្ឋានគ្រឹះលើគ្រប់ផ្នែកទាំងអស់នៃការរៀនសូត្រ
- រៀបចំបណ្ណាល័យបច្ចេកវិទ្យាអប់រំពហុភាសា

- **ការគាំទ្រដល់ការអប់រំពហុភាសាដែលមានគុណភាពល្អគឺផ្តោតលើ**
  - ភាពជាម្ចាស់ ភាពពាក់ព័ន្ធ និងការចូលរួមរបស់សហគមន៍
  - គ្រូបង្រៀនដែលបានបណ្តុះបណ្តាល មានជំនាញ និងមានសមត្ថភាពក្នុងការអភិវឌ្ឍភាសាកំណើត វិធីសាស្រ្តអប់រំពហុភាសា និងមានការយល់ដឹងពីយេនឌ័រ
  - ការអភិវឌ្ឍកម្មវិធីសិក្សា និងសម្ភារសិក្សាដែលទូលំទូលាយ និងសមស្របតាមវប្បធម៌
  - ភាពជាដៃគូអន្តរភ្នាក់ងារ
  - ការវាយតម្លៃសមស្របដែលឆ្លុះបញ្ចាំងពីបទពិសោធនៃការអប់រំពហុភាសា
- **ភស្តុតាងជាច្រើនជុំវិញការអប់រំពហុភាសាបានបង្ហាញពីអត្ថប្រយោជន៍សំខាន់មួយចំនួនដូចជា**
  - សម្រាប់កុមារជនជាតិដើមភាគតិច ពួកគាត់នឹងចូលរួមក្នុងការសិក្សាច្រើនជាងមុន ឆ្លើយតបសំណួររបស់លោកគ្រូ អ្នកគ្រូ និងចូលរួមបានស្មើភាពគ្នា
  - សម្រាប់ឪពុកម្តាយជាជនជាតិដើមភាគតិច ពួកគាត់អាចចូលរួមក្នុងការសិក្សារបស់កូនៗ គាំទ្រដល់គ្រូបង្រៀន និងចូលរួមក្នុងសកម្មភាពនានារបស់សាលារៀន
  - សម្រាប់សហគមន៍ជនជាតិដើមភាគតិច ពួកគាត់អាចថែរក្សាបាននូវភាសា និងអត្តសញ្ញាណវប្បធម៌ផ្ទាល់ខ្លួនរបស់ពួកគាត់ ពេលដែលពួកគាត់ចូលរួមយ៉ាងសកម្មជាមួយវប្បធម៌ផ្សេងទៀតនៃមនុស្សភាគច្រើន
  - សម្រាប់ការសិក្សា នឹងមានលទ្ធផលសិក្សាប្រសើរឡើង អត្រាបោះបង់ការសិក្សាមានការធ្លាក់ចុះ និងកម្រិតនៃភាពស្ទាត់ជំនាញខ្ពស់ជាងមុនសម្រាប់ភាសាទាំងពីរ គឺភាសាកំណើតរបស់អ្នកសិក្សា និងភាសាផ្លូវការផ្សេងៗទៀត
  - សម្រាប់ប្រព័ន្ធអប់រំ ការសិក្សាដែលប្រសើរឡើងមានន័យថាមានការប្រើប្រាស់ធនធានយ៉ាងមានប្រសិទ្ធផលដែលនាំឱ្យមានការសន្សំសំចៃពេលវេលា (គ្រូបង្រៀន និងរដ្ឋបាល) និងថវិកាទាំងរយៈពេលមធ្យម និងរយៈពេលវែង
  - សម្រាប់ជីវភាពរស់នៅ ការសិក្សាពិតប្រាកដ និងជំនាញភាសាដែលប្រសើរមានន័យថាទទួលបានឱកាសការងារ និងសហគមន៍ដែលមានសន្តិភាពជាងមុន

ភស្តុតាងក៏បានបង្ហាញផងដែរថាការចេះច្រើនជាងមួយភាសា គឺជាធនធានដែលនាំឱ្យមានសមិទ្ធិផលខ្ពស់ជាងមុននៅក្នុងកម្មវិធីសិក្សាទាំងអស់ និងជាការប្រើប្រាស់ធនធានមនុស្សកាន់តែប្រសើរឡើងសម្រាប់វិស័យសេដ្ឋកិច្ចរបស់ប្រទេស។ ម្យ៉ាងវិញទៀតការចេះភាសាច្រើនជាងមួយភាសាជំរុញឱ្យមានការគោរពខ្លួនឯង មានអត្តសញ្ញាណខ្លួនឯង និងមានអាកប្បកិរិយាជាវិជ្ជមានចំពោះការសិក្សារៀនសូត្រ និងនាំឱ្យមានភាពសុខដុមរមនា និងភាពពេញចិត្តក្នុងសង្គមកាន់តែច្រើនឡើង។

## ១០.៤ អនុសាសន៍វាយតម្លៃផែនការសកម្មភាពជាតិ ស្តីពីការអប់រំពហុភាសា២០១៥-២០១៨

- ផែនការសកម្មភាពជាតិ ស្តីពីការអប់រំពហុភាសា២០១៥-២០១៨

ផែនការសកម្មភាពជាតិស្តីពីការអប់រំពហុភាសា ២០១៥-២០១៨ បានដាក់ចេញនូវគោលបំណង០៤សំខាន់ៗ (១)ដើម្បីធានាយ៉ាងណាឱ្យកុមារា កុមារីជនជាតិដើមភាគតិច អាចទទួលបានការអប់រំប្រកបដោយគុណភាព និងឆ្លើយតបទៅនឹងការអប់រំសម្រាប់ទាំងអស់គ្នា (២)ដើម្បីកសាងសមត្ថភាពរបស់មន្ត្រីអប់រំនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង និងពិនិត្យតាមដានការអនុវត្តការអប់រំពហុភាសា (៣)ដើម្បីពង្រីកការផ្តល់ការអប់រំពហុភាសា

នៅតាមខេត្តពាក់ព័ន្ធ (៤)ដើម្បីលើកកម្ពស់គុណភាពនៃការអប់រំពហុភាសា តាមរយៈគណៈកម្មការទ្រទ្រង់សាលារៀន មាតាបិតា និងអាជ្ញាធរមូលដ្ឋាន។ ផែនការនេះមានយុទ្ធសាស្ត្រចំនួន០៦សម្រាប់អនុវត្ត (១)ការកសាងសមត្ថភាពជាពិសេសដល់គ្រូ និងការបណ្តុះបណ្តាលគ្រូ (២)ផ្តល់សម្ភារបង្រៀន និងរៀន (៣)ការសម្របសម្រួលទិន្នន័យ និងព័ត៌មាន ការពិនិត្យតាមដាន និងវាយតម្លៃ (៤)ការពង្រីកការផ្តល់សេវាអប់រំពហុភាសា (៥)ហេដ្ឋារចនាសម្ព័ន្ធ និងធនធាន (៦)សាលារៀនសហគមន៍

## អនុសាសន៍វាយតម្លៃផែនការសកម្មភាពជាតិ ស្តីពីការអប់រំពហុភាសា ២០១៥-២០១៨

ក្រសួងអប់រំ យុវជន និងកីឡា ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍ សហការជាមួយនឹងអ្នកទទួលបន្ទុកនៅថ្នាក់កណ្តាល ថ្នាក់ខេត្ត ស្ថាប័នសិក្សាស្រាវជ្រាវ អាជ្ញាធរមូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាល និងអ្នកកាន់សិទ្ធិចម្បងដូចជាអង្គការជាជនជាតិដើមភាគតិច កុមារ និងមាតាបិតាជាដើម៖

- បន្តរៀបចំផែនការសកម្មភាពស្តីពីការអប់រំពហុភាសា ២០១៩-២០២៣ ដោយដាក់ចេញនូវយុទ្ធសាស្ត្រ និងសកម្មភាពដែលមានការប៉ាន់ប្រមាណចំណាយច្បាស់លាស់ និងកំណត់ពីគណនេយ្យភាពការរៀបចំរបាយការណ៍ និងការវាយតម្លៃ។ ពង្រីកផែនការសកម្មភាពនេះបន្តិចម្តងៗ ដើម្បីបញ្ចូលភាសាជនជាតិដើមភាគតិចបន្ថែម។
- ពង្រឹងសមត្ថភាពប្រព័ន្ធ និងស្ថាប័ន របស់ក្រសួង អប់រំ យុវជន និងកីឡា ដើម្បីអនុវត្តផែនការនេះ រួមទាំងជ្រើសរើសបុគ្គលិកជនជាតិដើមភាគតិចបន្ថែមទៀត ដើម្បីបម្រើការងារនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដល់ការអភិវឌ្ឍសមត្ថភាពនាយកដ្ឋានអប់រំពិសេស និងរៀបចំរចនាសម្ព័ន្ធ ឱ្យបានសកម្មក្រោមការដឹកនាំរបស់មន្ត្រីជាន់ខ្ពស់នៃក្រសួងអប់រំ យុវជន និងកីឡា ដើម្បីធានាឱ្យមានកិច្ចសហការអន្តរនាយកដ្ឋាន។
- បង្កើនគុណភាពមត្តេយ្យសិក្សាអប់រំពហុភាសា និងសុខដុមនីយកម្មការអប់រំពហុភាសានៅកម្រិតមត្តេយ្យសិក្សា ដោយផ្តល់ការគាំទ្រដល់មត្តេយ្យសិក្សាសហគមន៍អប់រំពហុភាសា ដើម្បីបំពេញលក្ខណៈវិនិច្ឆ័យជាមត្តេយ្យសិក្សាសហគមន៍ស្តង់ដា ដូចមានចែងក្នុងអនុក្រឹត្យលេខ ២៤៥ អនក្រ.បក ស្តីពីការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍។
- បង្កើនគុណភាព បរិមាណ និងការរក្សាភាពគង់វង្សនៃគ្រូ ដែលធ្វើការងារតាមសាលាបឋមសិក្សាអប់រំពហុភាសា គ្រូឧទ្ទេសជនជាតិដើមភាគតិច តាមរយៈការបង្កើនការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសដល់អ្នកដែលមានភារកិច្ច ត្រូវបំពេញនៅថ្នាក់ក្រោមជាតិសម្រាប់រៀបចំការបណ្តុះបណ្តាល និងកិច្ចសហការជាមួយដៃគូអភិវឌ្ឍពាក់ព័ន្ធនឹងជនជាតិដើមភាគតិច។ ត្រៀមរៀបចំសាលាគរុកោសល្យខេត្ត ដើម្បីឱ្យសាលាទាំងនេះ អាចផ្តល់ការគាំទ្រដល់គ្រូជនជាតិដើមភាគតិច ក្នុងការអនុវត្តការងារអប់រំពហុភាសា។
- ពិនិត្យឡើងវិញ និងបន្តកម្មវិធីសិក្សា និងធនធានសម្រាប់ការអប់រំពហុភាសាដើម្បីធ្វើឱ្យកម្មវិធីសិក្សានេះកាន់តែមានភាពប្រសើរជាងមុន បន្ថែមខ្លឹមសារពាក់ព័ន្ធនឹងវប្បធម៌ឱ្យកាន់តែមានលក្ខណៈសម្បូរបែបបញ្ចូលធនធានដែលរៀបចំដោយអង្គការមិនមែនរដ្ឋាភិបាល និងជំរុញឱ្យមានការចូលរួមពីកុមារ សមាជិក សហគមន៍ និងដៃគូអភិវឌ្ឍពាក់ព័ន្ធនឹងជនជាតិដើមភាគតិច។

- បង្កើនការយល់ដឹងអំពីសិទ្ធិកុមារ និងគុណតម្លៃសង្គមនៃផែនការសម្មភាពស្ដីពីការអប់រំពហុភាសា តាមរយៈយុទ្ធនាការបង្កើនការយល់ដឹងជាសាធារណៈ និងពង្រឹងការស្វែងយល់ពីទស្សនទាននេះ តាមរយៈការបណ្ដុះបណ្ដាលដល់គ្រូបង្រៀន គ្រូឧទ្ទេស និងមន្ត្រីទទួលបន្ទុកជាជនជាតិជាអាទិភាព។
- កែលម្អប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ ដូចជាការបែងចែកទិន្នន័យ តាមយេនឌ័រ ជាតិពន្ធ និងភាសា និងភាគបែងដែលពាក់ពន្ធ័ដើម្បីកំណត់ពីវិសាលភាពប្រមូលទិន្នន័យតាមប្រព័ន្ធឌីជីថល និងទម្រង់របាយការណ៍ដែលមានលក្ខណៈស្តង់ដា។
- បង្កើតភាពជាដៃគូរវាងសាកលវិទ្យាល័យក្នុងស្រុក និងអន្តរជាតិ ដើម្បីរៀបចំតេស្តលទ្ធផលសិក្សាដោយប្រើប្រាស់ភាសាជនជាតិដើមភាគតិច សិក្សាពីការអនុវត្តដែលមានសក្តានុពលដូចជាការពង្រីកការអប់រំពហុភាសាដល់សិស្សថ្នាក់ទី៦ និងវាយតម្លៃលទ្ធផលត្រឡប់នៃការអប់រំពហុភាសា។

## ១០.៥ ស្ថិតិជនជាតិដើមភាគតិចនៅប្រទេសកម្ពុជា

| ខេត្ត | ចំនួនប៉ាន់ស្មានប្រជាជន ជនជាតិដើមភាគតិច | ចំនួនប៉ាន់ស្មាននៃកុមារជនជាតិ ដើមភាគតិច(៣-៥ឆ្នាំ) | ចំនួនប៉ាន់ស្មាននៃកុមារជន ជាតិដើមភាគតិច (៦-១៧ឆ្នាំ) |
|---|---|---|---|
| រតនគិរី | ១១៧ ១២៩ | ៧ ៣៩៦ | ៣៥ ៧៤៣ |
| មណ្ឌលគិរី | ៤១ ៩៦៤ | ៣ ០២១ | ១៣ ២៦៣ |
| ស្ទឹងត្រែង | ៤ ៩១២ | ៧១៨ | ៣ ១២៧ |
| ក្រចេះ | ១៣ ១៤១ | ៣ ៧៩០ | ១៥ ៣៩៤ |
| ព្រះវិហារ | ៦ ១៣៦ | | |
| សរុប | ១៨៣ ២៨២ | ១៤ ៩២៥ | ៦៧ ៥២៧ |

****ដកស្រង់ចេញពីផែនការសកម្មភាពជាតិស្តីពីការអប់រំពហុភាសាឆ្នាំ ២០១៥-២០១៨(ទំព័រទី២១ ២៤ និងទី២៥)*

## ១០.៦ គំរូអប់រំពហុភាសាសម្រាប់ការអប់រំក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធនៅកម្ពុជា

- **គំរូអប់រំពហុភាសាសម្រាប់ការអប់រំក្រៅប្រព័ន្ធ**

| | | |
|---|---|---|
| ឆ្នាំទី៣ | ភាសាកំណើត (L1) ១០%<br>-បន្តការអាន និងសរសេរភាសាកំណើត | ភាសាខ្មែរ ៩០%<br>-រៀនអាន និងសរសេរភាសាខ្មែរឱ្យស្ទាត់ |
| ឆ្នាំទី២ | ភាសាកំណើត (L1) ៥០%<br>-រៀនអាន និងសរសេរភាសាកំណើតឱ្យស្ទាត់ | ភាសាខ្មែរ៥០%<br>-រៀនអាន និងសរសេរភាសាខ្មែរ |
| ឆ្នាំទី១ | ភាសាកំណើត (L1)៩០%<br>-រៀនអាន និងសរសេរភាសាកំណើត | ភាសាខ្មែរ ១០%<br>-រៀននិយាយភាសាខ្មែរ |

*តារាងទី១៖ គំរូអប់រំពហុភាសាក្រៅប្រព័ន្ធប្រភពពី(ICC)*

## គំរូអប់រំពហុភាសាសម្រាប់ការអប់រំក្នុងប្រព័ន្ធសម្រាប់មត្តេយ្យសិក្សា និងបឋមសិក្សា

| គំរូអប់រំពហុភាសាសម្រាប់បឋមសិក្សា | | |
|---|---|---|
| ថ្នាក់ទី៤ ដល់ទី៦ | ភាសាខ្មែរ ១០០% | |
| ថ្នាក់ទី៣ | ភាសាកំណើត (L1) ៣០%<br>- សិក្សាសង្គម ១៥%<br>- ភាសាកំណើត ១៥% | ភាសាខ្មែរ (L2) ៧០%<br>-ភាសាខ្មែរ ៤៥%<br>-គណិតវិទ្យា ១៥%<br>-សិក្សាសង្គម ១០% |
| ថ្នាក់ទី២ | ភាសាកំណើត (L1) ៦០%<br>-ភាសាកំណើត ២៥%<br>-សិក្សាសង្គម ៣៥% | ភាសាខ្មែរ (L2) ៤០%<br>-ភាសាខ្មែរ ២៥%<br>-គណិតវិទ្យា ១៥% |
| ថ្នាក់ទី១ | ភាសាកំណើត (L1) ៨០%<br>-ភាសាកំណើត ៣០%<br>-គណិតវិទ្យា ១៥%<br>-សិក្សាសង្គម ៣៥% | ភាសាខ្មែរ (L2) ២០%<br>-សម្រាប់តែការនិយាយប៉ុណ្ណោះ |
| កម្រិតមត្តេយ្យសិក្សា | កុមារអាយុ៣ និង៤ឆ្នាំ | កុមារអាយុ៥ឆ្នាំ |
| ឆមាសទី១ | និយាយភាសាកំណើត | ភាសាកំណើត |
| ឆមាសទី២ | និយាយភាសាកំណើត | ភាសាខ្មែរ២០នាទីក្នុងមួយថ្ងៃជារៀងរាល់ថ្ងៃ |

*តារាងទី២៖ គំរូអប់រំពហុភាសាសម្រាប់បឋមសិក្សា និងមត្តេយ្យសិក្សា*

## ១០.៧ ចំណោលចំនួនសាលារៀន គ្រូ និងសិស្សអប់រំពហុភាសា

- **ការអនុវត្តកម្មវិធីអប់រំពហុភាសាសម្រាប់មត្តេយ្យសិក្សា**
  - ចំណោលចំនួនថ្នាក់មត្តេយ្យសិក្សាអប់រំពហុភាសា

| ខេត្ត | ចំនួនថ្នាក់ | មត្តេយ្យសិក្សាអប់រំពហុភាសា | | | | | ចំនួនថ្នាក់ |
|---|---|---|---|---|---|---|---|
| | ១៧-១៨ | ១៨-១៩ | ១៩-២០ | ២០-២១ | ២១-២២ | ២២-២៣ | សរុប |
| រតនគិរី | ៦១ | ៧៣ | ៧៥ | ៧៧ | ៧៩ | ៨១ | ៨១ |
| មណ្ឌលគិរី | ៩ | ១០ | ១១ | ១២ | ១៣ | ១៤ | ១៤ |
| ស្ទឹងត្រែង | ១០ | ១០ | ១០ | ១១ | ១២ | ១៣ | ១៣ |
| ក្រចេះ | ៨ | ៨ | ១០ | ១២ | ១២ | ១២ | ១២ |
| ព្រះវិហារ | ៦ | ៦ | ៦ | ៧ | ៧ | ៧ | ៧ |
| សរុប | ៩៤ | ១០៧ | ១១២ | ១១៩ | ១២៣ | ១២៧ | ១២៧ |

- ចំណោលចំនួនគ្រូមត្តេយ្យសិក្សាអប់រំពហុភាសា

| ខេត្ត | ចំនួនគ្រូ | គ្រូមត្តេយ្យសិក្សាអប់រំពហុភាសា | | | | | ចំនួនគ្រូ |
|---|---|---|---|---|---|---|---|
| | ១៧-១៨ | ១៨-១៩ | ១៩-២០ | ២០-២១ | ២១-២២ | ២២-២៣ | សរុប |
| រតនគិរី | ៦១ | ៧៣ | ៧៥ | ៧៧ | ៧៩ | ៨១ | ៨១ |
| មណ្ឌលគិរី | ៩ | ១០ | ១១ | ១២ | ១៣ | ១៤ | ១៤ |
| ស្ទឹងត្រែង | ១០ | ១០ | ១០ | ១១ | ១២ | ១៣ | ១៣ |
| ក្រចេះ | ៨ | ៨ | ១០ | ១២ | ១២ | ១២ | ១២ |
| ព្រះវិហារ | ៦ | ៦ | ៦ | ៧ | ៧ | ៧ | ៧ |
| សរុប | ៩៤ | ១០៧ | ១១២ | ១១៩ | ១២៣ | ១២៧ | ១២៧ |

- ចំណោលចំនួនគ្រូមត្តេយ្យសិក្សាសហគមន៍ស្តង់ដាអប់រំពហុភាសា (មត្តេយ្យសិក្សាសហគមន៍ស្តង់ដាអប្បបរមា)

| ខេត្ត | ចំនួនគ្រូ | គ្រូមត្តេយ្យសិក្សាសហគមន៍ស្តង់ដាអប់រំពហុភាសា | | | | | ចំនួនគ្រូ |
|---|---|---|---|---|---|---|---|
| | ១៧-១៨ | ១៨-១៩ | ១៩-២០ | ២០-២១ | ២១-២២ | ២២-២៣ | សរុប |
| រតនគិរី | ៦ | ៨ | ១០ | ១២ | ១៤ | ១៦ | ១៦ |
| មណ្ឌលគិរី | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៧ |
| ស្ទឹងត្រែង | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៧ |
| ក្រចេះ | ៤ | ៤ | ៥ | ៥ | ៥ | ៥ | ៥ |
| ព្រះវិហារ | ១ | ២ | ៣ | ៤ | ៥ | ៥ | ៥ |
| សរុប | ១៥ | ២០ | ២៦ | ៣១ | ៣៦ | ៤០ | ៤០ |

- ចំណោលចំនួនសិស្សជនជាតិដើមភាគតិចចូលរៀននៅថ្នាក់មត្តេយ្យសិក្សាសម្រាប់កម្មវិធីអប់រំពហុភាសា

| ខេត្ត | ចំនួនសិស្ស | សិស្សមត្តេយ្យសិក្សាអប់រំពហុភាសា | | | | | ចំនួនសិស្សសរុប |
|---|---|---|---|---|---|---|---|
| | ១៧-១៨ | ១៨-១៩ | ១៩-២០ | ២០-២១ | ២១-២២ | ២២-២៣ | |
| រតនគិរី | ១ ១០១ | ១ ៤១០ | ១ ៤៥០ | ១ ៤៩០ | ១ ៥៣០ | ១ ៥៧០ | ១ ៥៧០ |
| មណ្ឌលគិរី | ១៩៧ | ២៣៦ | ២៥៧ | ២៧៧ | ២៩៧ | ៣១៧ | ៣១៧ |
| ស្ទឹងត្រែង | ២០៧ | ១៩២ | ១៩២ | ២១៧ | ២៤២ | ២៤២ | ២៤២ |
| ក្រចេះ | ១៧០ | ១៥៦ | ១៩៩ | ២៤៩ | ២៤៩ | ២៤៩ | ២៤៩ |
| ព្រះវិហារ | ១២៣ | ១៣២ | ១៣២ | ១៥៣ | ១៥៣ | ១៥៣ | ១៥៣ |
| សរុប | ១ ៧៩៨ | ២ ១២៧ | ២ ២៣០ | ២ ៣៨៦ | ២ ៤៧១ | ២ ៥៣១ | ២ ៥៣១ |

- **ការអនុវត្តកម្មវិធីអប់រំពហុភាសាសម្រាប់បឋមសិក្សា**

  - ចំណោលចំនួនសាលាបឋមសិក្សាអប់រំពហុភាសា

| ខេត្ត | ចំនួនសាលា | សាលាបឋមសិក្សាអប់រំពហុភាសា | | | | | ចំនួនសាលាសរុប |
|---|---|---|---|---|---|---|---|
| | ១៧-១៨ | ១៨-១៩ | ១៩-២០ | ២០-២១ | ២១-២២ | ២២-២៣ | |
| រតនគិរី | ៣៤ | ៣៤ | ៣៤ | ៣៦ | ៣៨ | ៤០ | ៤០ |
| មណ្ឌលគិរី | ២៣ | ២៣ | ២៥ | ២៧ | ២៩ | ៣១ | ៣១ |
| ស្ទឹងត្រែង | ៩ | ៩ | ៩ | ៩ | ៩ | ៩ | ៩ |
| ក្រចេះ | ១៤ | ១៤ | ១៥ | ១៦ | ១៧ | ១៨ | ១៨ |
| សរុប | ៨០ | ៨០ | ៨៣ | ៨៨ | ៩៣ | ៩៨ | ៩៨ |

** *ការអនុវត្តកម្មវិធីអប់រំពហុភាសាសម្រាប់ខេត្តរតនគិរីនឹងមានការកើនឡើងចំពោះសាលារៀនដែលអនុវត្តកម្មវិធីអប់រំពហុភាសាភាសាចារាយចំនួន៤សាលារៀនចាប់ពីឆ្នាំ ២០២០-២០២១*

  - ចំណោលចំនួនគ្រូបឋមសិក្សាអប់រំពហុភាសា

| ខេត្ត | ចំនួនគ្រូ | គ្រូបឋមសិក្សាអប់រំពហុភាសា | | | | | ចំនួនគ្រូសរុប |
|---|---|---|---|---|---|---|---|
| | ១៧-១៨ | ១៨-១៩ | ១៩-២០ | ២០-២១ | ២១-២២ | ២២-២៣ | |
| រតនគិរី | ៧៩ | ៧៩ | ៨៤ | ៨៨ | ៩២ | ៩៤ | ៩៤ |
| មណ្ឌលគិរី | ៥០ | ៥៨ | ៦២ | ៦៨ | ៧២ | ៧៨ | ៧៨ |
| ស្ទឹងត្រែង | ៣០ | ៣០ | ៣០ | ៣០ | ៣០ | ៣០ | ៣០ |
| ក្រចេះ | ៣៨ | ៤១ | ៤៣ | ៤៥ | ៤៨ | ៥១ | ៥១ |
| សរុប | ១៩៧ | ២០៨ | ២១៩ | ២៣១ | ២៤២ | ២៥៣ | ២៥៣ |

  - ចំណោលចំនួនសិស្សជនជាតិដើមភាគតិចចូលរៀននៅសាលាបឋមសិក្សាសម្រាប់កម្មវិធីអប់រំពហុភាសា

| ខេត្ត | ចំនួនសិស្ស | ចំនួនសិស្សរៀននៅថ្នាក់អប់រំពហុភាសា | | | | | ចំនួនសិស្សសរុប |
|---|---|---|---|---|---|---|---|
| | ១៧-១៨ | ១៨-១៩ | ១៩-២០ | ២០-២១ | ២១-២២ | ២២-២៣ | |
| រតនគិរី | ២ ៥០៣ | ២ ៣៥៦ | ២ ៥០៦ | ២ ៥៥១ | ២ ៦៣១ | ២ ៧១១ | ២ ៧១១ |
| មណ្ឌលគិរី | ១ ០២៥ | ១ ២៥២ | ១ ២៩២ | ១ ៣៧២ | ១ ៥២២ | ១ ៦៧២ | ១ ៦៧២ |
| ស្ទឹងត្រែង | ៦២០ | ៦០៧ | ៦០៧ | ៦០៧ | ៦០៧ | ៦០៧ | ៦០៧ |
| ក្រចេះ | ៧១៨ | ៧៣៩ | ៧៧៤ | ៨០៩ | ៨៥៩ | ៩០៩ | ៩០៩ |
| សរុប | ៤ ៨៦៦ | ៤ ៩៥៤ | ៥ ១៧៩ | ៥ ៣៣៩ | ៥ ៦១៩ | ៥ ៨៩៩ | ៥ ៨៩៩ |

- **ការអនុវត្តកម្មវិធីអប់រំពហុភាសាសម្រាប់ថ្នាក់អក្ខរកម្ម**

  - ចំណោលចំនួនថ្នាក់អក្ខរកម្មអប់រំពហុភាសា

| ខេត្ត | ចំនួនថ្នាក់ | ថ្នាក់អក្ខរកម្មអប់រំពហុភាសា | | | | | ចំនួនថ្នាក់ |
|---|---|---|---|---|---|---|---|
| | ១៧-១៨ | ១៨-១៩ | ១៩-២០ | ២០-២១ | ២១-២២ | ២២-២៣ | សរុប |
| រតនគិរី | | | ២ | ៤ | ៦ | ៨ | ៨ |
| មណ្ឌលគិរី | | | ១ | ២ | ៣ | ៤ | ៤ |
| ស្ទឹងត្រែង | | | | ២ | ៤ | ៦ | ៦ |
| ក្រចេះ | | | | ១ | ២ | ៣ | ៣ |
| សរុប | | | ៣ | ៩ | ១៥ | ២១ | ២១ |

  - ចំណោលចំនួនគ្រូអក្ខរកម្មអប់រំពហុភាសា

| ខេត្ត | ចំនួនគ្រូ | គ្រូអក្ខរកម្មអប់រំពហុភាសា | | | | | ចំនួនគ្រូ |
|---|---|---|---|---|---|---|---|
| | ១៧-១៨ | ១៨-១៩ | ១៩-២០ | ២០-២១ | ២១-២២ | ២២-២៣ | សរុប |
| រតនគិរី | | | ២ | ៤ | ៦ | ៨ | ៨ |
| មណ្ឌលគិរី | | | ១ | ២ | ៣ | ៤ | ៤ |
| ស្ទឹងត្រែង | | | | ២ | ៤ | ៦ | ៦ |
| ក្រចេះ | | | | ១ | ២ | ៣ | ៣ |
| សរុប | | | ៣ | ៩ | ១៥ | ២១ | ២១ |

  - ចំណោលចំនួនសិស្សជនជាតិដើមភាគតិចចូលរៀននៅថ្នាក់អក្ខរកម្មអប់រំពហុភាសា

| ខេត្ត | ចំនួនសិស្ស | សិស្សអក្ខរកម្មអប់រំពហុភាសា | | | | | ចំនួនសិស្ស |
|---|---|---|---|---|---|---|---|
| | ១៧-១៨ | ១៨-១៩ | ១៩-២០ | ២០-២១ | ២១-២២ | ២២-២៣ | សរុប |
| រតនគិរី | | | ៤០ | ៨០ | ១២០ | ១៦០ | ១៦០ |
| មណ្ឌលគិរី | | | ២០ | ៤០ | ៦០ | ៨០ | ៨០ |
| ស្ទឹងត្រែង | | | | ៤០ | ៨០ | ១២០ | ១២០ |
| ក្រចេះ | | | | ២០ | ៤០ | ៦០ | ៦០ |
| សរុប | | | ៦០ | ១៨០ | ៣០០ | ៤២០ | ៤២០ |

****ការអនុវត្តកម្មវិធីអក្ខរកម្មអប់រំពហុភាសាបានអនុវត្តដោយដៃគូអភិវឌ្ឍប៉ុន្តែពិបាកក្នុងការប្រមូលស្ថិតិមូលដ្ឋាន*

## ១០.៨ ចំណោលចំនួនសិស្សជនជាតិដើមភាគតិចទទួលអាហារូបករណ៍

- ចំណោលចំនួនសិស្សជនជាតិដើមភាគតិចទទួលអាហារូបករណ៍បឋមសិក្សា(ថ្នាក់ទី១-ថ្នាក់ទី៦)

| ខេត្ត | ចំនួនសិស្ស | ចំនួនសិស្សជនជាតិដើមភាគតិចទទួលបានអាហារូបករណ៍ | | | | | ចំនួនសរុប |
|---|---|---|---|---|---|---|---|
| | ១៧-១៨ | ១៨-១៩ | ១៩-២០ | ២០-២១ | ២១-២២ | ២២-២៣ | |
| រតនគិរី | | ១ ៣៩១ | ១ ៥៥០ | ១ ៥៥០ | ១ ៥៥០ | ១ ៥៥០ | |
| មណ្ឌលគិរី | | ៩១៣ | ៩២០ | ៩២០ | ៩២០ | ៩២០ | |
| ស្ទឹងត្រែង | | ៥០ | ១០០ | ១០០ | ១០០ | ១០០ | |
| ក្រចេះ | | ៤៨៧ | ៥០០ | ៥០០ | ៥០០ | ៥០០ | |
| ព្រះវិហារ | | ១០៥ | ១១០ | ១១០ | ១១០ | ១១០ | |
| សរុប | | ២ ៩៤៦ | ២ ៦៨០ | ២ ៦៨០ | ២ ៦៨០ | ២ ៦៨០ | |

*** សិស្សជនជាតិដើមភាគតិចដែលទទួលអាហារូបករណ៍ជាចំនួនសិស្សជនជាតិដើមភាគតិចដែលរៀននៅសាលាអនុវត្តកម្មវិធីអប់រំពហុភាសា និងនៅសាលាធម្មតាក្នុងខេត្តនីមួយៗ។ សម្រាប់ឆ្នាំ ២០១៧-២០១៨ បានអនុវត្តប៉ុន្តែមិនអាចរកស្ថិតិបានច្បាស់លាស់។ សិស្សម្នាក់អាចទទួលបានអាហារូករណ៍ទាំង៦កម្រិតថ្នាក់ ឬតាមជាក់ស្តែង។*

- ចំណោលចំនួនសិស្សជនជាតិដើមភាគតិចទទួលអាហារូបករណ៍មធ្យមសិក្សាបឋមភូមិស្នាក់នៅអន្តេវាសិកដ្ឋាន (ខេត្តរតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ក្រចេះ និងខេត្តព្រះវិហារ)

| ខេត្ត | ចំនួនសិស្ស | ចំនួនសិស្សជនជាតិដើមភាគតិច | | | | | ចំនួនសរុប |
|---|---|---|---|---|---|---|---|
| | ១៧-១៨ | ១៨-១៩ | ១៩-២០ | ២០-២១ | ២១-២២ | ២២-២៣ | |
| ថ្នាក់ទី ៧ | | ២០ | | | | | |
| ថ្នាក់ទី៨ | | | ២០ | | | | |
| ថ្នាក់ទី៩ | | | | ២០ | | | |
| សរុប | | ២០ | ២០ | ២០ | | | |

- ចំណោលចំនួនសិស្សជនជាតិដើមភាគតិចទទួលអាហារូបករណ៍មធ្យមសិក្សាទុតិយភូមិ (ខេត្តរតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ក្រចេះ និងខេត្តព្រះវិហារ)

| ខេត្ត | ចំនួនសិស្ស | ចំនួនសិស្សជនជាតិដើមភាគតិច | | | | | ចំនួនសរុប |
|---|---|---|---|---|---|---|---|
| | ១៧-១៨ | ១៨-១៩ | ១៩-២០ | ២០-២១ | ២១-២២ | ២២-២៣ | |
| ថ្នាក់ទី១០ | | ២៥៥ | ២៥០ | ២៥០ | | | |
| ថ្នាក់ទី ១១ | ៥៨២ | ២៥០ | ២៥៥ | ២៥០ | ២៥០ | | |
| ថ្នាក់ទី១២ | ៥១០ | ៥៥១ | ២៥០ | ២៥០ | ២៥០ | ២៥០ | |
| សរុប | ១ ០៩២ | ១ ០៥៦ | ៧៥៥ | ៧៥០ | ៥០០ | ២៥០ | |

***សិស្សម្នាក់អាចទទួលអាហារូបករណ៍ទាំងបីកម្រិតថ្នាក់ ឬតាមជាក់ស្តែង។*

- ចំណោលចំនួនគរុសិស្សជនជាតិដើមភាគតិចទទួលអាហារូបករណ៍
  ( សគមម  មគភ.សត សគវខ.ពហ និងសគវ.ក្រច)

| ខេត្ត | ចំនួនគរុសិស្ស | ចំនួនគរុសិស្សជនជាតិដើមភាគតិច | | | | | ចំនួនគរុសិស្សសរុប |
|---|---|---|---|---|---|---|---|
| | ១៧-១៨ | ១៨-១៩ | ១៩-២០ | ២០-២១ | ២១-២២ | ២២-២៣ | |
| ឆ្នាំទី១ | | ៥០ | ៥០ | ៥០ | ៥០ | | |
| ឆ្នាំទី២ | | | ៥០ | ៥០ | ៥០ | ៥០ | |
| សរុប | | ៥០ | ១០០ | ១០០ | ១០០ | ៥០ | |

*** គរុសិស្សម្នាក់អាចទទួលអាហារូបករណ៍ទាំងពីរឆ្នាំសិក្សា ឬតាមជាក់ស្តែង។*